Free
សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

REMEDIUM PHARMACY
ឱសថស្ថានរ៉ីមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម • ការវេចខ្ចប់ឱសថ • ការលាយផ្សំឱសថ
• បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ • ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

# ក្រុមមេដឹកនាំផ្ដាច់ការមក កាលីហ្វ័រញ៉ាខាងត្បូង

A crowd of dictators is coming to Southern California - LA Times






















**១-**ប្រទេសកម្ពុជា : **ហ៊ុន សែន**
**២-**ប្រទេសថៃ: **ប្រាយុទ ចាន់-អូចារ**
**៣-**ប្រទេសម៉ាឡេស៊ី : **ណាយីប រ៉ាស្នាក**
**៤-**ប្រទេសប្រ៊ុយណេ : **ហាសាណាល់ ប៊ូលគីយ៉ា**
**៥-**ប្រទេសភូមា : **ថាន សែន**
**៦-**ប្រទេសឡាវ : **ជុំមាលី សាយាសូន**
**៧-**ប្រទេសវៀតណាម : **ង្វៀង តាំង ឌុង**

**ដោយ: ខ្មែរផុស.ស.រ.អា.**

កាសែត"ឡូសង់ជើឡេសថាម"សរសេរកាលពីថ្ងៃសៅរ៍ទី១៣ នៅពេលរៀបចំជំនួបមេដឹកនាំអាស៊ានទាំង១០ នៅថ្ងៃទី១៥-១៦នេះថា "លោកប្រធានាធិបតី បារ៉ាក់ អូបាមា កំពុងរៀបចំទទួលកំពូលមេដឹកនាំផ្ដាច់ការមកពីអាស៊ីនៅរដ្ឋកាលីហ្វ័រញ៉ាខាងត្បូងដែលក្រៅតែពីប្រទេសតែ៣ប៉ុណ្ណោះ មានប្រមុខរដ្ឋាភិបាលបានជាប់ឆ្នោត គឺឥណ្ឌូណេស៊ី ហ្វីលីពីន នឹងសឹង្ហបូរី"។ រីឯលោក ជន ស៊ីហ្វតុន នាយកផ្ដល់យោបល់អង្គការ"ឃ្លាំមើលការគោរពសិទ្ធមនុស្ស-អេស៊ាវ៉ៃច" បានសម្ដែងការព្រួយបារម្ភថា កិច្ចប្រជុំ "សានីឡិនស៊ុបមីយ"នៅកាលីហ្វ័រញ៉ាទោះជាលោក អូបាម៉ានិយាយអ្វីក៏ដោយនឹងផ្ដល់កម្លាំងដល់មេដឹកនាំដែលបានចាប់អ្នកកាសែតដាក់គុកដែលបានបង្ក្រាបបាតុករសន្តិភាពនឹងបំផ្លាញស្ថាប័នប្រជាធិបតេយ្យដោយរដ្ឋប្រហារ"។

**មេដឹកនាំផ្ដាច់ការនិយមទាំង៧រូបនោះមានៈ**

**១-**ប្រទេសខ្មែរ ហ៊ុន សែន អាយុ៦២ឆ្នាំគ្រប់គ្រងប្រទេស៣០ឆ្នាំមកហើយ ជានាយករដ្ឋមន្ត្រីយូរជាងគេនៅអាស៊ី ជាអតីតមេទ័ពខ្មែរក្រហម ដែលសម្លាប់ប្រជាជនក្នុងប្រទេសអស់១ភាគ៤នៃនគរខ្លួនឯង។ ក្រុមរក្សាសន្តិសុខរបស់គាត់ **តទៅទំព័រទី ០៣**

## វិចារណកថា

### ឆ្នាំ២០១៦ត្រៀមជូនដំណើរជើយជំនះដល់កម្ពុជា


ពិន សំខុន

**ដោយ: ពិន សំខុន**

ថ្ងៃដាច់ឆ្នាំកន្លងទៅហើយគេឮតែអ្នកនយោបាយជាន់ខ្ពស់ខ្មែរសន្យាថានឹងកាត់ដៃចោល ប្រសិនបើខ្លួនសុំឱ្យព្រះមហាក្សត្រលើកលែងទោសឱ្យលោក សម រង្ស៊ី សាជាថ្មីម្ដងទៀត... ដល់ថ្ងៃដាច់ឆ្នាំទៅហើយដែរ ភាគីរដ្ឋាភិបាលខ្មែរនឹងរដ្ឋាភិបាលវៀតណាមនៅតែបង្ខំចិត្តសម្ភោធបង្គោលព្រំប្រទល់ដែនថ្មីទៀត ហាក់ដូចជាជូនពរជ័យនៃឆ្នាំ២០១៦នេះ មិនឱ្យរៀបចំការបោះឆ្នោតឱ្យបានស្មើរភាពគ្នាបន្ថែមពីលើនេះប្រជាពលរដ្ឋទទួលបាននូវការបង្កើនគំនុំដ៏ជ្រាលជ្រៅនៅពេលដែលដឹងថា ព្រំប្រទល់ថ្មីដែលទើបសម្ភោធនេះអាចជាការឱ្យដីទៅវៀតណាមជាផ្លូវការ ។ មានតែក្រុមបិសាចទេ ដែលជូនពរប្រជាពលរដ្ឋខ្លួនឯងឱ្យបានប្រកបតែ"សេចក្ដីទុក្ខ"គ្រប់ប្រការបែបនេះ ។

សេចក្ដីប្រាថ្នារបស់ថ្នាក់ដឹកនាំរបៀបនេះគឺជាជង្រុកនៃទុក្ខទោសរបស់ពលរដ្ឋមិនថានៅក្នុងបក្សសង្គ្រោះជាតិ ឬក៏បក្សប្រជាជននោះទេ ហើយបើមើលឱ្យបានឆ្ងាយជាងនេះ

**តទៅទំព័រទី ១៨**

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554
ឱសថស្ថានសេនជូរី :
យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!


• ផ្ដល់សេវាដល់ទីលំនៅ
• ខ្ចប់ឱសថតាមបំណង
• ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត
937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476


SAVE THE DATE
APA HERITAGE MONTH
CELEBRATION
MAY 6, 2016
6:00-11PM
SAMPAO MEAS Hall
450 Chelmsford St.Lowell, MA 01851
Lowell, MA
The 6th Annual
KhmerPost USA
Media & Community Gala
For sponsorship opportunity, please contact Soben Pin at 978-656-8141
or visit our website at www.khmerpostusa.com

# តមកទំព័រទី ០១ ក្រុមមេដឹកនាំផ្តាច់ការមកកាលីហ្វ័រនីញ៉ា

ចាប់អ្នកទិទានដាក់គុក សម្លាប់អ្នកប្រឆាំង កំពុងបង្ហាញអំពើឃោរឃៅធ្វើទារុណកម្មសម្លាប់មនុស្សនឹងរឹបអូសយកដីពលរដ្ឋ។

**២-**ប្រទេសថៃ: ប្រាយុទ ចាន់-អូចារ អាយុ ៦១ឆ្នាំ ឡើងកាន់អំណាចដោយរដ្ឋប្រហារយោធា នៅឆ្នាំ២០១៤ គាត់បិទមាត់ក្រុមអ្នកសារព័ត៌មានណាដែលនិយាយខ្លាំងៗនឹងចាប់ដាក់គុកដល់អ្នកតវ៉ាប្រឆាំង។ នៅពេលសហរដ្ឋកំពុងតាមមើលពីករណី"សម្ព័ន្ធមិត្ត" ប្រាយុទ្ធ ងាកទៅរកចិន... ឆ្នាំមុនគាត់ចាប់បញ្ជូនជនជាតិចិន២នាក់ចាប់ជនជាតិ"អ៊ុយហ្គួរ ឥស្លាម"១០០នាក់ គេចខ្លួនរកសិទ្ធិជ្រកកោនបញ្ជូនទៅស្រុកចិនវិញ ទោះជាក្រុមសិទ្ធិមនុស្សព្រមានថា អ្នកទាំងនោះប្រឈមមុខនឹងការដាក់ទណ្ឌកម្មសងសឹកក៏ដោយ។

**៣-**ប្រទេសម៉ាឡេស៊ីៈ ណាយីប រ៉ាស្ហាក អាយុ៦២ឆ្នាំ ធ្វើនាយករដ្ឋមន្ត្រីតាំងពីឆ្នាំ២០០៩ ឆ្នាំមុនគាត់បានដាក់ច្បាប់ដ៏ចម្រូងចម្រាសមួយដែលឱ្យអំណាចគាត់ដាក់គុកអ្នកណាដែលធ្វើឱ្យរង្គោះរង្គើអំណាចរដ្ឋ បានន័យថា អ្នកប្រឆាំងនឹងគាត់។ នៅឆ្នាំមុននេះដែរគាត់មានរឿងអាស្រូវហិរញ្ញវត្ថុក្នុងការវេរលុយ៧០០លានដុល្លាចូលក្នុងហិបគាត់។

**៤-**ប្រទេសប្រ៊ូណេៈ ហាសាណាល់ ប៊ូលគីយ៉ា អាយុ៦៧ឆ្នាំ ដឹកនាំប្រទេសទាំងពីឆ្នាំ១៩៦៨ ជាស្តេចស៊ុលតង់ មកពីសហគនសាន់នីដ៏តូចមួយគ្រប់គ្រងនៅកោះមួយជាប់នឹង"បណេអូ"។ ស្តេចនេះមានសម្បត្តិ២០ពាន់លាន ជាមនុស្សក្នុងចំណោមអ្នកមានជាងគេបង្អស់នៅលើពិភពលោក។ គាត់មានអំណាចដាក់ទោសសម្លាប់ចោលនរណាហ៊ានប្រមាទគម្ពីរ"កូរាន" -ទោសសាហាយស្មន់នឹងទោសរួមភេទដូចគ្នាត្រូវដាក់ទោសគប់នឹងដុំថ្ម។ នាដាច់ឆ្នាំកន្លងទៅគាត់ដាក់ទោសជាប់គុក៥ឆ្នាំ នរណាហ៊ានធ្វើបុណ្យ"គ្រីស្ទីស"ជាសាធារណ។


បាតុករ ខ្មែរ ឡាវ ភូមា វៀតណាម...លើកបដារប្រឆាំងនឹងវត្តមានមេផ្តាច់ការ

**៥-**ប្រទេសភូមាៈ ធាន សែន ជាអ្នកដឹកនាំលើកដោយគ្មានការបោះឆ្នោតដោយយោធា ចុងឆ្នាំ២០១៥ បានចាញ់ឆ្នោតយ៉ាងសន្ធឹកប្រឈមមុខនឹង"គណបក្សសម្ព័ន្ធប្រជាធិបតេយ្យជាតិ"ដឹកនាំដោយលោកស្រី អូនសាំន ស៊ូជី ជ័យលាភីរង្វាន់ណូបែល។ លោក ធាន សែន នឹងអស់អំណាចនៅខែមិនាខាងមុខ តែគាត់នៅតែជាតំណាងប្រទេសភូមាមកចូលប្រជុំនៅអាមេរិកថ្ងៃ១៥កុម្ភៈនេះ។

**៦-**ប្រទេសឡាវៈ ជុំមាលី សាយាសូន អាយុ៧៩ឆ្នាំ មេដឹកនាំគណបក្សប្រជាជនបដិវត្តឡាវ ជាគណបក្សតែមួយនៅក្នុងប្រទេស ហើយមានការគាបសង្កត់ប្រជាពលរដ្ឋយ៉ាងតឹងតែងបំផុតក្នុងលោកៈ គណបក្សកុម្មុយនិស្ត ត្រួតពិនិត្យការប្រើអិនធ័រណេតអ្នកប្រឆាំងត្រូវចាប់ខ្លួនដោយមិនចាំបាច់មានជំនុំជំរះ អ្នកកាសែតអាចនឹងជាប់គុក១៥ឆ្នាំ បើហ៊ានទិទៀនរដ្ឋាភិបាល។ ជុំម៉ាលិទើបនឹងទិញផ្ទះមួយតម្លៃ៦១ម៉ឺនកន្លះក្នុងប្រទេសដែលពលរដ្ឋមានប្រាក់ចំណូលប្រចាំឆ្នាំ១៤៥០ដុល្លា។ មហាសន្និបាទបក្សទើបនឹងបញ្ចប់តំណែងលោក ដូច្នេះលោកនឹកចេញពីតំណែងខែមិនានេះហើយ។

**៧-**ប្រទេសវៀតណាមៈ ង្វៀង តាំង ឌុង អាយុ ៦៦ឆ្នាំ គឺជាមនុស្សមានអំណាចខ្លាំងក្នុងបក្សកុម្មុយនិស្តវៀតណាម ដែលជាមនុស្សជិតដិតនឹងឧត្តមសេនីយ **តទៅទំព័រទី ១០**

## មាតិការរឿង

Issue 195 from Feb.19th to Mar.03th. 2016


១-ខ្ញុំត្រូវបានប៉ូលិសពិន័យ..........០៥
២-អង្គការ "ធ្វើ-វា-ដោយខ្លួនឯង"..........០៦
៣-ធ្វើឱ្យប្រឡាយទឹកភ្លឺឡើង..........០៧
៤-តំបន់ក្រេតធើមើរីមេករលេ..........០៨
៥-ចូលឆ្នាំចិននៅឡូវែល..........០៩
៦-ពលរដ្ឋខ្មែរនៅទីក្រុងឡូវែលទាមទារឱ្យក្រសួង..........១១
៧-ល្បែងរង់ចាំ..........១២
៨-ការផ្សាយបន្តផ្ទាល់ "ការបោះឆ្នោតបឋម"..........១៩


**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852


ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណួស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

Allstate. You're in good hands.

Veasna Chhay
Licensed Sales Producer
Home/Auto/Life MA & RI

Allstate Insurance Company
1535 Smith Street
North Providence, RI 02911

Phone 508-282-5820/Cell 401-588-4358
veasnachhay2@allstate.com





Personalized service.
Trusted advice.

" Also I do income tax return service for MA and RI for "Veasna Tax Preparation Serivices'."

ការិយាល័យច្បាប់
រ៉ូសា និង តាំង





Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា





Andrew ´Bunna´ Taing, Esq.
មេធាវី អែន ទ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

កំណាងក្តីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទំនាស់ផ្នែកអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com

# CENTURY PHARMACY & OPTICAL

937 Gorham St | ALL MAJOR INSURANCES ACCEPTED | Tel: 978-455-6554

យើងជា
ឱសថ
ស្ថានមួយ
ដែលអាចផ្តល់
ភាពជឿជាក់
ដល់គ្រួសារ
លោកអ្នក




យើងខ្ញុំ
សូមជូនពរ
មហាប្រសើរ
ដល់លោក
អ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ែរ, និងកាតធានារ៉ាប់រងសុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្ញើថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។ ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

លេខទូរស័ព្ទ 978-455-6554

លេខហ្វាក់ 978-455-9476

937 Gorham St Lowell, MA, 01852

# ខ្ញុំត្រូវបានប៉ូលីសពិន័យ

## “I got a ticket”

**ដោយៈ វ៉ដែរ ពិន**

**ឡូវែលៈ** ទើបបានចូលសញ្ជាតិអាមេរិកាំងមិនទាន់បានប៉ុន្មានថ្ងៃផង ស្រាប់តែត្រូវបានប៉ូលិសចាប់ហើយ"ផាក"យ៉ាងចាស់ដៃ។ ធម្មតាខ្ញុំតែងតែភ័យ បារម្ភ ឃើញប៉ូលីស តែងប្រកាសចុះចាញ់ហើយជាស្រេច ពីព្រោះពេលយើងមានកាតបៃតង"គ្រីនខត"មិនឱ្យចាញ់សម្លុតប៉ូលីសម្ដេចបាន ពីព្រោះគ្មាននរណាការពារយើងក្រៅតែពីរកមេធាវី ហើយចាយលុយដូចគេជះចោលទើបអាចរកយុត្តិធមិបានខ្លះ។ តែនៅថ្ងៃទី២មករាឆ្នាំ២០១៥ ប៉ូលិសចាប់លើកនេះ ស្រាប់តែមានកម្លាំងចិត្តមកពីណា ថាត្រូវប្រើសិទ្ធិថ្មីស្រឡាងរបស់ខ្លួន ដើម្បីតទល់ពួកនេះម្ដង!

ខ្ញុំនៅចាំនៅឡើយថា ថ្ងៃនោះ មេឃត្រជាក់ខ្លាំងណាស់ ធ្វើឱ្យមានជម្ងឺផ្ដាសាយពេញផ្ទះ ដូច្នេះត្រូវចេញទៅទិញថ្នាំក្អកនឹងផ្ដាសាយ នៅឯ "វ៉លគ្រីន"នៅផ្លូវ"ផ្លែនស្ទ្រីត"ទើបបានរួចជីវិត។ ទិញបានថ្នាំនៅម៉ោង១២ថ្ងៃត្រង់រួចហើយ ចេញមកវិញក៏ឡើងតាមផ្លូវ"អិចប្រេសវេយ" ក៏ស្រាប់តែឃើញឡានប៉ូលីសមួយចតខាងមុខកំពុងចាប់អ្នកបើកបរម្នាក់ឈប់នៅពីមុខឡានគាត់។ លោកប៉ូលីសនោះគាត់បញ្ចប់ការងារជាមួយឡានពីមុខគាត់រួចហើយ ក៏ត្រឡប់ត្រៀមបើកទ្វារចូលឡានគាត់។ ឃើញគាត់រៀបនឹងបើកទ្វារឡានដូច្នោះខ្ញុំក៏ឈប់ឡានទុកឱ្យផ្លូវទូលាយសិន ទើបទៅមុខទៀតបាន។ រីឯលោកប៉ូលិសនោះវិញឃើញខ្ញុំឈប់ឡាននៅលើផ្លូវដែលគេ"ត្រូវបើកបរលឿន អិចប្រេសវេយ" ក៏ថយទៅមុខឡានគាត់វិញ ទុកផ្លូវឱ្យខ្ញុំទៅមុខបាន ខ្ញុំក៏បន្តដំណើរទៅមុខទៀត។ គ្រាន់តែផុតឡានប៉ូលីសនោះបន្តិចខ្ញុំក្រឡេកទៅក្រោយតាមកញ្ចក់ ស្រាប់តែឃើញលោកប៉ូលិសនោះ ប្រញាប់ប្រញាល់រត់ចូលរថយន្តគាត់ប្រដេញតាមខ្ញុំភ្លាម ដោយដាក់ "ស៊ីរ៉ែន"ផង។ ខ្ញុំក៏បញ្ឈប់ឡានប៉ូលីសក៏មកឈប់ពីក្រោយឡានខ្ញុំលើផ្លូវថ្នល់ពាក់កណ្ដាលលើចិញ្ចើមថ្នល់ពាក់កណ្ដាល ដូចដែលគាត់ធ្វើពីមុននេះបន្តិចជាមួយរថយន្តមុន។ ប៉ូលីសសួរខ្ញុំដោយមានទឹកមុខមាំថា"អ្នកឯងដឹងខ្ញុំចាប់អ្នកឯងដោយសារអ្វីទេ?"ទម្លាប់តែខ្លាចប៉ូលីស ហើយក៏មិនចង់បង្ហាញភាពរឹងរូសដាក់គេក៏ឆ្លើយតបថា"ខ្ញុំដឹង"គាត់ក៏ទារសំបុត្រស្នាមឡាន នឹង "អាយឌី" យកទៅពិនិត្យក្នុងឡានគាត់ ខ្ញុំនឹកថា"មិនបានធ្វើអ្វីខុសច្បាប់ទេ" តែក៏នឹកមិនឃើញថា តើអាចនឹងមានកំហុសអ្វីបានទេ! នៅពេលដែលលោកប៉ូលិសនោះត្រឡប់មកវិញ ប្រគល់លិខិតទាំងអស់មកខ្ញុំវិញ ថែមទាំងលិខិត "ផាក" មួយតម្លៃ១០៥ដុល្លាមកជាមួយផង ដោយគាត់ចារថា "ឈប់ឡាននៅលើផ្លូវដែលបើកលឿន"ខ្ញុំហួសចិត្តដោយត្រូវប៉ូលីសយល់ថា ខ្ញុំចង់ឈប់លេងនៅទីនោះ! ប៉ូលីសនិយាយប្រាប់ខ្ញុំថា ឡានផ្លូវនេះបើកលឿនៗណាស់ អ្នកមិនអាចឈប់បានទេ អ្នកដឹងទេ! ខ្ញុំឆ្លើយ"បាទ"ម្ដងទៀត ដោយមិនចាំច្បាស់ថា បើបង់"ផាក"អស់១០៥ដុល្លាទៅរឿងត្រូវចប់ ហើយក៏មិនខាតបង់ពេលទៀត! ហេតុយ៉ាងនេះធ្វើឱ្យខ្ញុំគិតថា"បើធ្វើជាល្ងង់ប្រហែលជាចំណេញជាង"...តែនៅពេលនេះ ខ្ញុំមានពេលច្រើនដោយខ្ញុំចូលនិវត្តន៍ហើយ ហើយសញ្ជាតិអាមេរិកាំង




ដែលខ្ញុំត្រូវមានទោសដោយបានធ្វើរំលងច្បាប់មុនគេ គាត់បានរៀបរាប់យ៉ាងវែង លំអិត លំអដោយមាត្រានៃច្បាប់ទៅជាមួយផង ថាខ្ញុំមិនព្រមបើកឡានគេចទៅរកផ្លូវបន្ទាត់ខាងឆ្វេងបែរជាឈប់ឡានលើផ្លូវដែលគេកំពុងបើកលឿនទៅវិញ ធ្វើឱ្យមានជាប់ឡានពីក្រោយទៀតផង... តាមសាច់រឿងសមតែខ្ញុំជាប់គុកមែន! តែខ្ញុំនៅតែមានជំនឿយ៉ាងមាំថា ខ្ញុំជាអ្នកបើកបរខំទប់កុំឱ្យមានគ្រោះថ្នាក់ដែលខ្ញុំមើលឃើញថា បង្កដោយប៉ូលីសម្នាក់នោះ នៅតែមានកម្លាំងលើច្បាប់នោះជានិច្ច។ ដល់វេនខ្ញុំការពារខ្លួនម្ដង ខ្ញុំបានបញ្ជាក់ថា សេចក្ដីរាយការរបស់ប៉ូលីសនោះ បានកើតរបៀបនោះមែន ប៉ុន្តែសម្រាប់ខ្ញុំដែលទើបចេញពីផ្លូវតូច"អិចស៊ីត"មិនទាន់បង្កើនល្បឿនឆ្លងទៅបន្ទាត់ឆ្វេងបាន ស្រាប់តែមកដល់ឡានប៉ូលីសដែលមានប៉ូលីសម្នាក់ត្រៀមបើកទ្វារឡានខ្លួន... លោកស្រីចៅក្រម សួរកាត់ថា ហេតុអ្វីក៏អ្នកមិនឆ្លងកាត់ចេញទៅបន្ទាត់មួយទៀតទៅ? ខ្ញុំតបថា លោកប៉ូលីសបានទទួលស្គាល់ថា ផ្លូវនោះមានឡានច្រើនហើយបើកលឿន ចំណែកខ្ញុំចេញពី"អិចស៊ីត"ភ្លាម មិនអាចបើកលឿនបានទេ ដូច្នេះទៅខាងឆ្វេងក៏អាចគ្រោះថ្នាក់ទៅមុខត្រង់ក៏អាចគ្រោះថ្នាក់ ខ្ញុំគ្មានជម្រើសក្រៅពីឈប់ឡានខ្ញុំសិន



ខ្ញុំបានឈប់យ៉ាងម៉េច ដែលធ្វើឱ្យខ្ញុំខុសនឹងច្បាប់នោះ? បូលីសបន្ថែមថា "បើអ្នកមិនពេញចិត្តនឹងសេចក្ដីសម្រេចនេះទេ អ្នកអាចនឹងទៅតវ៉ាទៅតុលាការបាន!" ខ្ញុំក៏តបដោយស្វ័យប្រវត្តិទៅវិញថា"អាយវៀល"បានន័យថា ខ្ញុំនឹងទៅ។

ខ្ញុំបើកឡានត្រឡប់មកផ្ទះវិញ មិនអស់ចិត្តថា "លើកនេះខុសពីរាល់ដង នៅពេលខ្លួនខ្ញុំទទួលការផាកពិន័យ ហេតុអ្វីក៏មិនច្បាស់ជាបានធ្វើខុសយ៉ាងដូច្នោះ? គួរឱ្យចំឡែកដែរ! ដូច្នេះលោកប៉ូលីសនេះ ច្បាស់ជាខកខ្លួនហើយលើកនេះ ខ្ញុំច្បាស់ជាមិនសុខចិត្តចុះចាញ់ដូចមុនៗទៀតទេ ពីមុនទោះជាត្រូវឬខុសក៏ដោយខ្ញុំទទួលខុសទាំងអស់កុំឱ្យតែមានរឿងវែងឆ្ងាយ។

ខ្ញុំបានផ្ញើរសំបុត្រតវ៉ាភ្លាម ក្រោមការលើកទឹកចិត្តពីមិត្តភ័ក្ត្រខ្លះដែលយល់ថា មានប៉ូលីសខ្លះមិនចូលចិត្តពួកអាស៊ីយើងទេ ថាយើងល្ងង់ណាស់ "ផាក"របៀបណាក៏គ្មានតវ៉ាអីដែរ! មែនពីមុនមកខ្ញុំមិនដែលតវ៉ានឹងការផាកពិន័យមែន។

គ្រាន់តែផ្ដើមតវ៉ាភ្លាម ខ្ញុំត្រូវបង់ប្រាក់៥០ដុល្លាដើម្បីឱ្យខ្ញុំបានជួបនឹងក្រឡាបញ្ជីម្នាក់នឹងតំណាងប៉ូលីសម្នាក់មកពិនិត្យករណី"ពិន័យ"របស់ខ្ញុំ នៅ២ខែក្រោយមក។ នៅពេលបានជួបក្រឡាបញ្ជីនឹងតំណាងប៉ូលីស លោកប៉ូលីសហាក់ដូចជាយល់ករណីដែលធ្វើឱ្យខ្ញុំជំទាស់នឹងការ"ពិន័យ"លើរូបខ្ញុំ តែក្រឡាបញ្ជីតំណាងតុលាការមិនយល់ស្របនៅតែបញ្ជូនខ្ញុំទៅ"ឧទ្ធរណ៍"ទាល់តែបាន ហើយខ្ញុំត្រូវបង់៥០ដុល្លាទៀត ដើម្បីឱ្យបានទៅជួបចៅក្រម។ លើកនេះអយុត្តិធមិពេញបន្ទុក ប្រសិនថែមទៀត ដែលនឹងបើកឱកាសឱ្យខ្ញុំអាចតវ៉ាវិតតែឆ្ងាយជាងទៅតុលាការបាន ដូច្នេះត្រូវសាកល្បងប្រើសិទ្ធនោះ តើអយុត្តិធមិវានឹងទៅដល់ណា? ស្មានតែគេភ្លេចខ្ញុំបាត់ទៅហើយ ៨ខែក្រោយមកមានដីការកោះហៅឱ្យទៅសាវនាការម្ដងទៀត។

ថ្ងៃទី១០ខែកុម្ភៈឆ្នាំ២០១៦ នៅសាលលេខ៦នៃតុលាការចរាចរក្រុងឡូវែលពេលនោះមានចៅក្រមស្ត្រីចំណាស់ម្នាក់មកជាអធិបតីឃើញមានអំណាចពេញបន្ទុក តែទឹកមុខញញឹមមិនដូចលោកប៉ូលីសដែលមានអំណាចដែរ តែត្រូវតែធ្វើមុខកាចជានិច្ចនោះទេ។ ក្រឡាបញ្ជីបានហៅឈ្មោះខ្ញុំ ជាករណីមុនគេប្រឈមមុខនឹងតំណាងប៉ូលិសម្នាក់ដែលគ្មានឯកសណ្ឋាននៅក្បែរគ្នាតែមិនងាកមើលទៅណាផ្សេងក្រៅតែពីតុលាការទេ។ គាត់បានត្រូវអញ្ជើញឱ្យរាយការពីហេតុបានទេ!។ ថ្វីត្បិតតែលោកប៉ូលីសនៅតែទទូចថាខ្ញុំនៅតែអាចមើលឃើញឡានប៉ូលីសពីចម្ងាយ ហើយគេចចេញបាន តែលោកស្រីចៅក្រមបានសម្រេច កាត់សេចក្ដីថា "ខ្ញុំឥតមានកំហុសទេ" រួចទៅហើយ។

ខ្ញុំចេញមកវិញមានការពេញចិត្តនឹងសេចក្ដីសម្រេចចិត្តថា"បានការពារសិទ្ធិរបស់ខ្លួន"ដោយបានចូលសញ្ជាតិដណ្ដើម"សិទ្ធស្មើនឹងអ្នកដទៃ"បានរាប់ទាំងសិទ្ធិអំណាចប៉ូលីសផង...ប្រសិនបើចាញ់ក្ដីពេលនេះ ហើយបើទៅ"ឧទ្ធរណ៍□ទៀតបានត្រូវរកមេធាវីឱ្យទៅជួយការពារក្ដីនៅទីនោះទៀត...បើគេមិនឱ្យទៅ"ឧទ្ធរណ៍"ទេ ខ្ញុំត្រូវចេញថ្លៃគេ"ផាក"ខ្ពស់ជាងមុនមែន តែត្រូវស្វែងរក"កម្លាំងនយោបាយ"ទៅកែច្បាប់ "អយុត្តិធមិ"នោះចេញ ទើបអស់ចិត្ត៕

# អង្គការ"ធ្វើ_វា_ដោយខ្លួនឯង" របស់ទីក្រុងឡូវែលនឹងធ្វើរាត្រីភីស្សា

**ប្រែសម្រួលដោយ ពារាយុទ្ធ ហង្ស**

អង្គការ"ធ្វើ-វា-ដោយខ្លួនឯង"របស់ទីក្រុងឡូវែល (Do-it-Yourself Lowell) គឺពិតជារវល់ណាស់ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ នឹងខ្លួនគ្រោងនឹងរៀបចំប្រារព្ធពិធីជាមួយហៅថា រាត្រីភីស្សា (Pizza Night.) ដែលជាព្រឹត្តិការណ៍សាធារណៈមួយរួមបញ្ចូលទៅដោយ ភីស្សា តន្ត្រី នឹងការបង្ហាញអំពីគំរោងបច្ចុប្បន្ននឹងគំរោងនៅថ្ងៃអនាគតរបស់ខ្លួន។ គោលបំណងរបស់អង្គការនេះគឺកំពុងតែព្យាយាមធ្វើឱ្យគំនិត គំរោង នឹងព្រឹត្តិការណ៍ទាំងអស់នោះ ពិតជាកើតមានឡើងនៅក្នុងទីក្រុងឡូវែល។

ព្រឹត្តិការណ៍នេះ នឹងធ្វើឡើងនៅថ្ងៃទី២ ខែមិនា នារាត្រីម៉ោងប្រាំពីរយប់ នៅឯ អាន់អាធិតងាលើរី (UnchARTed Gallery) ហើយគេនឹងចាត់ទុកកម្មវិធីនោះជាកម្មវិធីធំរបស់ខ្លួនប្រចាំរដូវនារឆ្នាំ២០១៦។

អូរ្សរា អេរិកសុន (Aurora Erickson) បានមានប្រសាសន៍ថា "ពួកយើងពិតជាអរគុណចំពោះសហគមន៍នឹងជាពិសេសក្រុមស្ម័គ្រចិត្តរបស់ពួកយើងដែលបានជួយគាំទ្រ" "ពួកយើងចង់អួតនូវអ្វីដែលពួកគេបានធ្វើនឹងអ្វីដែលពួកយើងបានធ្វើរួមគ្នានឹងនេះគឺជាលេសដ៏ល្អមួយក្នុងការចែករំលែកភីស្សាដ៏ឆ្ងាញ់នៅក្នុងកណ្តាលក្រុង(downtown)!"

ក្រុម DIY Lowell បានរៀបចំរួចរាល់ជាស្រេចបាច់នូវកម្មវិធីទេសភាពបែតងនៅឯអាងស្តុកទឹកគ្រីស្ទានហៀល (Christian Hill) ហើយខ្លួនបានរៃអង្គាសលុយបានរាប់ពាន់ដុល្លារនឹងចាប់ផ្តើមរៀបចំនូវកង់សិល្បៈបង្ហាញនឹងអនុម័តនៅកន្លែងសុវត្ថិភាពផ្លូវប្រវត្តិសាស្ត្រដែលធ្វើឡើងបណ្តោះអាសន្ននឹងបង្ហាញនូវអត្តសញ្ញាណនៃប្រភពដើមឈើដែលមានផ្លែ ដើម្បីឱ្យយកទៅបណ្តុះនៅឯតំបន់សាធារណៈ ហើយនឹងចាប់ផ្តើមពិភាក្សាដើម្បីបញ្ចូលទូរដាក់ឥវ៉ាន់ក្នុងគោលបំណងចែករំលែកនូវសៀវភៅដោយមិនគិតថ្លៃនៅឯចំណតឡានក្រុង។

ប្រធានរបស់ DIY Lowell ក៏បានរៀបចំគំរោងមួយដើម្បីសហប្រតិបត្តិការជាមួយនឹងអាជីវកម្មតូចនឹងម្ចាស់ទ្រព្យសម្បត្តិផ្សេងៗ ដើម្បីរៀបចំតុបតែងនៅពីផ្នែកខាងមុខហាងទាំងអស់នៃទីក្រុងដោនថោនកាលពីខែវិច្ឆិកា។ ក្រុម DIY Lowell គឺជាក្រុមស្ម័គ្រចិត្តមេដឹកនាំដែលបានទទួលការបណ្តុះបណ្តាលមកពីស្ថាប័នក្នុងតំបន់សហគមន៍ប្រធាននឹងរៀនពីគ្នាទៅវិញទៅមក។

អេរិកសុនបានបន្ថែមទៀតថា ដ៏ពួកយើងពិតជាមោទនភាពណាស់ចំពោះក្រុមស្ម័គ្រចិត្តទាំងនោះ ពីព្រោះពួកគេមិនដែលធ្វើរឿងបែបនេះពីមុនមកទេ ដូចជា ការរៃអង្គាស ការបង្កើតនូវកិច្ចប្រជុំ ឬការចានាឱ្យបានការអនុម័ត ហើយអ្វីទាំងអស់នេះ បានធ្វើឱ្យពួកគេកំពុងតែមានអារម្មណ៍ពុះកញ្ជ្រោលក្នុងការសំរេចនូវការងារផ្សេងៗបន្ថែមទៀត នាពេលអនាគត។

បន្ថែមពីនេះទៀតព្រឹត្តិការណ៍នេះបើកជូនក្រុមអ្នកស្ម័គ្រចិត្តរបស់ DIY Lowell ដោយ

តទៅទំព័រទី១០



# DIY Lowell to Celebrate Community Projects with Pizza Night

**Lowell, MA - February 8, 2016**

Do-it-Yourself Lowell has been very busy over the past year, and plans to celebrate with "DIY Lowell Night," a public event with pizza, music, and presentations about its current projects and future plans. The grassroots organization is committed to making ideas for small-scale community projects and events in Lowell a reality. The event, to be held on March 2, 7:00 pm, at UnchARTed Gallery, will also serve as a kick-off to their 2016 season.



"We want to thank the community and especially our volunteers for their support," says DIY Lowell Co-Founder Aurora Erickson. "We want to show off what they've done and what we're going to do together-and it's a great excuse to share some great pizza downtown!"

DIY Lowell groups have already organized a leaf-viewing party at the Reservoir at Christian Hill, raised thousands of dollars and begun design of two downtown artistic bicycle racks, mapped out and secured approvals for a pop-up temporary history trail, identified a

**Contiued to page 10**




Clemente Park Chiropractic

Chetra A. Keo, D.C.

851 Middlesex Street. Lowell, MA 01851

**(978) 937-1492**

**Treatments**

- Neck Pain
- Back Pain
- Lower Back Pain

- ឈឺ-ក
- ឈឺខ្នង
- ឈឺចង្កេះ-ខ្នង

- Automobile Injuries
- Personal Injuries
- Work Related Injuries

- គ្រោះថ្នាក់រថយន្ត
- រងរបួស
- របួសនៅកន្លែងធ្វើការ

WE ARE EXPANDING!

យើងនឹងបើកកន្លែងថ្មីមួយទៀត!

New Location in Lynn Opening in October!

383 Chestnut St. Lynn, MA 01904

# ធ្វើឱ្យប្រឡាយទឹកភ្លឺឡើង

**ដោយ Richard Howe Jr.**
**បកប្រែដោយ តារាយុទ្ធ ហង្ស**



Richard Howe

រាល់រដូវក្តៅទីក្រុងឡូវែលតែងតែធ្វើពិធីបុណ្យអុំទូកមួយក្នុងគោលបំណងជួយរំលឹកពលរដ្ឋក្រុងឡូវែលទាំងអស់អំពីសារៈសំខាន់នៃទឹកទន្លេនឹងវប្បធម៌អាស៊ីអាគ្នេយ៍។ ពិធីបុណ្យអុំទូករបស់ប្រជាជនកម្ពុជាក្នុងទីក្រុងឡូវែលបានជួយជំរុញអ្នកដឹកនាំរបស់ទីក្រុងមួយនេះឱ្យប្រើទស្សនៈថ្មីមើលទៅកាន់ប្រព័ន្ធប្រឡាយទឹក នឹងទឹកទន្លេរបស់ទីក្រុងមួយនេះ ជាធនធានដ៏សំខាន់ក្នុងការអភិវឌ្ឍន៏ វប្បធមិ សេដ្ឋកិច្ច នឹងការកំសាន្ត។

ដោយសារតែមានប្រឡាយច្រើនទីក្រុងនេះត្រូវបានគេហៅឈ្មោះថា វីនេស នៃអាមេរិកាំង (Venise of America)។ ប្រព័ន្ធប្រឡាយដំបូងដែលមានទីតាំងនៅ ផតាក់ខេត (Pawtucket) ត្រូវបានជីកសំរាប់ធ្វើនាវាចរណ៏នៅក្នុងឆ្នាំ១៧៩០។ ប្រលាយនេះត្រូវបានបំបែបជាបួនផ្លូវដោយអនុញ្ញាតឱ្យទូកដឹកជញ្ជូនផលិតផលពី ញូហេមឆឺរ(New Hampshire) ទៅកាន់មហាសមុទ្រអាត្លង់ទិកដោយឆ្លងកាត់ទឹកធ្លាក់មានកំពស់៣២វូត(32 foot) ដែលមានឈ្មោះថា ផតាក់ខេត នៅឯទន្លេ"មេរីកម៉ាក" (Merrimack River)។ នៅក្នុងឆ្នាំ១៨២០ រោងចក្រកប្បាសដំបូងរបស់ទីក្រុងមួយនេះក៏បានប្រើនូវប្រព័ន្ធប្រឡាយ"ផតាក់ខេត" ដើម្បីផលិតនូវថាមពលក្នុងការជួយផ្គត់ផ្គង់នៃដំណើរការរបស់ម៉ាស៊ីនត្បាញកប្បាស។ នៅពេលដែលមានរោងចក្រកប្បាសកាន់តែច្រើន ពេលនោះក៏នឹងមានប្រព័ន្ធប្រឡាយកាន់តែច្រើនដែរ។ បន្ទាប់មកទីក្រុងឡូវែលក៏ចាប់ផ្តើមមាននូវប្រព័ន្ធប្រឡាយដែលមានធំហំ៥.៦ មៃ (Miles) ដើម្បីឱ្យសមនូវកេរឈ្មោះទន្លេទាំងពីររបស់ខ្លួន គឺ មេរីម៉ាក (Merrimack) នឹង ខនខដ (Concord)។

កន្លងមកនេះ រោងចក្រកប្បាសត្រូវបានបិទនឹងមួយចំនួនបានរើចេញ។ ប៉ុន្តែប្រព័ន្ធប្រឡាយនឹងទឹកទន្លេគឺនៅដដែល។ ហេតុផលចំបងមួយដែលធ្វើឱ្យ"ឱទ្យានជាតិ"(National Park) មកកាន់ទីក្រុងឡូវែល គឺដោយសារតែប្រព័ន្ធប្រឡាយនេះ។ មួយឆ្នាំៗទូកសេវាកម្មរបស់ឱទ្យានជាតិបានដឹកភ្ញៀវទេសចរណ៏តាមរយៈប្រព័ន្ធប្រឡាយនឹង នៅលើទឹកទន្លេមេរីម៉ាក។ ផ្សេងពីនេះទៅទៀតតំរូវការភាគច្រើនមិនត្រូវបានប្រើតាមរយៈប្រឡាយទេ ដូច្នេះមនុស្សខ្លះកំពុងតែព្យាយាមផ្លាស់ប្តូរនូវប្រព័ន្ធប្រឡាយទាំងនោះ។

លោក ហ្វ្រេដ ហ្វូស (Fred Faust) ដែលជាប្រធានក្រុមហ៊ុនអចលនទ្រព្យក្រុមហ៊ុនអេដក្រុប នឹងលោកផលមារៀនដែលជានាយកប្រតិបត្តិនៃសហគមន៏ វប្បធម៌ទូទៅនៅសាកលវិទ្យាល័យឡូវែលមាសាឈូសេត (Umass Lowell) បានសិក្សាអំពី ថាតើទីក្រុងដ៏ទៃទៀតនៅជុំវិញពិភពលោកប្រើនូវប្រព័ន្ធប្រឡាយនឹងទឹកទន្លេដើម្បីទាក់ទាញនឹងបង្កើតការកំសាន្តចំពោះទីក្រុងរបស់គេនឹងភ្ញៀវទេសរណ៏យ៉ាងម៉េចដែរ ? លោក ផល នឹង ហ្វ្រេដ គិតថា ប្រព័ន្ធប្រលាយ នឹង ទន្លេគឺជាចំណុចកណ្តាលនៃសកម្មភាពប្រចាំថ្ងៃដែលទាក់ទងទៅនឹងការអភិវឌ្ឍន៏ វប្បធមិ ការសំសាន្ត និង សេដ្ឋកិច្ច។ ពួកគេមិនមានបំណងបង្កើតគំរោងអ្វីមួយដែលប៉ះពាល់ទៅនឹងប្រព័ន្ធទឹកទេ។ ប៉ុន្តែផ្ទុយទៅវិញពួកគេទាំងពីរចង់ជំរុញប្រជាជន និងអង្គការនៅក្នុងទីក្រុងឡូវែលឱ្យប្រើនូវការច្នៃប្រឌិតរបស់ខ្លួនដើម្បីធ្វើឱ្យមានការប្រើប្រាស់ដ៏ល្អមួយចំពោះប្រព័ន្ធទឹកនេះ។

ក្នុងពេលតែមួយរដ្ឋាភិបាលទីក្រុងឡូវែលគឺកំពុងបញ្ចូលនូវភ្លើងពណ៌ដ៏ឆើតឆាយនៅលើប្រឡាយ"មេរិកម៉ាក" ដែលជាកន្លែងសំរាប់ធ្វើនាវាចរណ៏ ចន្លោះអាគារទាំងពីររបស់សាលាវិទ្យាល័យឡូវែល។ ពន្លឺទាំងនេះនឹងត្រូវបានប្រើជាលើដំបូងនៅថ្ងៃបុណ្យរដូវរងា ហៅថា "វីនធើរវេស" (Winterfest) នៅថ្ងៃទី១៩ ដល់ ២០ ខែកុម្ភៈ នឹងប្រើដើម្បីបំភ្លឺ ទឹកទន្លេ ជញ្ជាំងប្រលាយ នឹងអាគារ នឹងដើមឈើនៅជិតទីនោះ។ ហើយពន្លឺទាំងនេះ អាចផ្លាស់ប្តូរពណ៌របស់វាអាស្រ័យទៅលើ រដូវ ឬក៏ព្រឹត្តិការណ៏ដែលប្រារព្ធ ហើយនឹងត្រូវប្រើប្រចាំឆ្នាំ។

ដោយមាននូវពន្លឺដ៏ខ្លាំងក្លា ស្រស់ស្អាត នឹងសមរម្យ អ្នកដឹកនាំនៅទីក្រុងទាំងនេះ បានអញ្ជើញម្ចាស់ទ្រព្យសម្បត្តិដ៏ទៃទៀត ដើម្បីឱ្យពួកគេបំភ្លឺនៅអាគាររបស់ពួកគេដើម្បីជួយធ្វើឱ្យទីក្រុងឡូវែលខ្លាយជាពន្លឺនៃប្រទេសអាមេរិកាំង៕

# Lighting Up The Canals

**By Richard Howe Jr.**

Every summer, the Southeast Asian Water Festival reminds all residents of Lowell of the importance of rivers to the people and cultures of Southeast Asia. The Cambodian people of Lowell and their annual water festival have helped inspire city leaders to look again at the rivers and canals of Lowell as important resources for culture, recreation, and economic development.



Photo by Andrew Howe

Lowell has been called the Venice of America because of all the canals in the city. The first canal - the Pawtucket - was dug in the 1790s as a transportation canal. Using four lock chambers, the Pawtucket Canal allowed boats carrying products from New Hampshire to the Atlantic Ocean to safely pass the 32-foot drop in the Merrimack River at Pawtucket Falls. In the 1820s, the first of the great cotton mills of Lowell used the Pawtucket Canal to generate power to run the machinery of the mills. As more mills were built, more canals were dug. Soon, Lowell had 5.6 miles of canals to complement its two rivers, the Merrimack and the Concord.

Over time, the cotton mills closed. Many were torn down. But the canals and the rivers remained. One of the main reasons the National Park came to Lowell in the 1970s was the canals. Each year, National Park Service tour boats carry thousands of visitors through the canals and onto the Merrimack River. Other than that, not much use is made of the canals. Some people are trying to change that.

Fred Faust, the owner of the Edge Group real estate company, and Paul Marion, the executive director of Community and Cultural Affairs at UMass Lowell, have studied how other cities around the world use their rivers and canals as attractions to entertain residents and to bring visitors to their cities. Paul and Fred see the canals and rivers of Lowell as the center of day-to-day activities related to culture, recreation, and economic development. They do not seek to impose a master plan from the top down. Instead, they want to motivate people and organizations in Lowell to use their own initiative and imagination to make better use of the waterways.

At the same time, the city government of Lowell is installing colorful LED lights on the Merrimack Canal where it runs between the two buildings of Lowell High School. These lights, which will be used for the first time during Winterfest (February 19 & 20), will light up the water, the canal walls, and the nearby trees and buildings. The lights can change color depending on the season or event being celebrated and will be used year-round.

With LED lighting now powerful, colorful, and affordable, city leaders invite other property owners to light up their buildings to help make Lowell the City of Lights of America.



# តំបន់គ្រេតធើមើរីមេកវាលេ

**បកប្រែដោយ តារាយុទ្ធ ហង្ស**

តំបន់គ្រេតធើមើរីមេកវាលេ Greater Merrimack Valley គឺជាកន្លែងល្អឥតខ្ចោះក្នុងការកំសាន្តនៅខាងក្រៅផ្ទះអំឡុងពេលរដូវរងារ ។ ជាផ្ទះនៃតំបន់ជិះស្គី Nashoba ដែលមានទីតាំងស្ថិតនៅភាគខាងជើងនៃទីក្រុងបូស្តុន វេសវ៉ូដ Westford រដ្ឋមាសាឈូសេត Massachusetts, បានបើកជាលើកដំបូងក្នុងឆ្នាំ ១៩៦៤ ។ កាលនោះ ខ្សែពួរត្រូវបានគេប្រើដើម្បីទាញឡើងចំណោទនឹងទឹកកកនារដូវត្រជាក់ គឺអាស្រ័យទាំងស្រុងទៅលើព្រិលធម្មជាតិ ។ ដោយសារតែមាភាពក្តៅនឹងសូ្តនារដូវរងារនោះ កាលបើជាលើកតំបូង គឺបានត្រឹមតែ១៤ថ្ងៃ! ផ្ទះសំណាក់មូលដ្ឋានដំបូងបង្កស់មានទៅដោយឥតគ្រួសដែលគេប្រើចង្ក្រានឃ្យូងមកដុតធ្វើជាកំដៅ ។ ហើយបុគ្គលិកដែលធ្វើការនៅទីនោះត្រូវជីកព្រិល នៅលើជំរាលភ្នំដោយសារតែខ្វះនូវម៉ាស៊ីន ។

នៅក្នុងឆ្នាំ១៩៧0 ណាសូបាវាលេ បានចាប់ផ្តើមពង្រីកនៅការទិញ ធីបារលីស(T-Bar lift) ដែលមាន កៅអីពីរ ឬ ក៏បីរ នៅក្នុងឆ្នាំ១៩៧៨ ។ បន្ទាប់មកក្នុងឆ្នាំ១៩៨0ណាសូបាវាលេបានបន្ថែមនៅ ទ្រីផលឆះលីស (Triple Chair Lift) ដែល





គេហៅថា "ឆេះChief" នឹងក្នុងឆ្នាំ១៩៩៤ ពួកគេបានបន្ថែម ទ្រីផលឆះលីសមួយទៀត ដែលគេហៅថា " សាន់ដេន Sundance"។ សព្វថ្ងៃនេះណាសូបាវាលេ មាននៅកៅអីបួន (4chair-lifts) ម៉ាស៊ីនសំរាប់ដឹកមនុស្សពីរ (2Conveyers) ហើយនឹងកន្សែពួរ៤ សំរាប់ឡើងភ្នំដែលមានចំណុះ ១១ ៦00 ក្នុងមួយម៉ោង ។

ណាសូបាវាលេ គឺតំបន់ដំបូងបំផុតដែរ នៅក្នុងប្រទេសដែលត្រូវបានអនុញ្ញាតឱ្យមានការជិះនៃស្គួរទឹកកក ។ ក្នុងកំឡុងឆ្នាំ១៩៨0 ណាសូបាវាលេបានបង្កើតនូវព្រឹត្តិការណ៍ដ៏ធំមួយក្នុងនោះមានការប្រកួតរវាងលោក ជេស ប្រូស៊ី (Jeff Brushie) ជេសុនវ៉ដ (Jason Ford) នឹង ថូដរីឆាត (Todd Richard) ។ថ្ងៃនេះ ណាសូបាវាលេ គឺជាកន្លែងដែលបើកបំរើការជិះស្គីផ្តល់ជូននូវមេរៀនជួលជិះស្គីនៅអំឡុងពេលរដូវរងារ ។ ក្នុងឆ្នាំ ២00១ ណាសូបាវាលេឧទ្យាន snowtubing ជ្រលងភ្នំបានបើកធំជាងគេរបស់អង់គ្លេសថ្មីហើយមានបួនផ្លូវ ១៦ និងជាង ៦00 បំពង់ព្រិល ។

បើ ទ្រាំត្រជាក់នៅដដែលហេតុអ្វីក៏មិនចេញក្រៅស្រូបនូវខ្យល់អាកាសបរិសុទ្ធ នឹងទទួលនូវបទពិសោធន៏ផ្សងព្រេងថ្មីមួយ នៅឯញូអ៊ីងលេន ។ ទីបញ្ចប់ជីវិតនៅការផ្សងព្រេងគឺត្រូវតែរៀន ។ ដូច្នេះអ្នកនៅរងចាំអ្វី? សូមេត្តាចូលទៅកាន់គេហទំព័រ www.merrimackval-ley.org បើចង់ដឹងនូវព័តិមានលំអិតទាក់ទងនូវសំបុត្រនឹងការផ្សយព្រេងពេញមួយយប់ ។ ពួកយើងសង្ឃឹមនឹងជួបអ្នកនៅទីនោះ ៕

# The Greater Merrimack Valley

**by Ded balanger**

The Greater Merrimack Valley is just the perfect place to enjoy the outdoors during the winter season. Home to Nashoba Valley Ski Area, located just north of Boston in Westford, Massachusetts, opened for its first season in 1964. Back then, rope tows were used to service four slopes and the winter season was dependent on Mother Nature for snow cover. Due to a wet, warm winter, the first season only lasted 14 days! The original base lodge consisted of a gravel floor and was heated by a pot-bellied stove. Staff had to pack the snow on the slopes with shovels due to a lack of grooming machines.

In the 70's Nashoba Valley began to expand with the purchase of the T-Bar lift, a double chair and a triple chair in 1978. Come 1986 the "Chief" Triple Chair Lift was added, followed by the "Sundance" triple in 1994. Today Nashoba Valley operates with 4 chairlifts, 2 conveyers, and 4 rope tows for an uphill capacity of 11,600 per hour.

Nashoba Valley was also one of the first area's in the country to allow snowboarding. During the 80's Nashoba hosted some of the largest events to date with names like Jeff Brushie, Jason Ford, and a very young Todd Richards competing. Today, Nashoba Valley is a full-service ski area, offering lessons, rentals, skiing, and snowboarding during the winter. In 2001 Nashoba Valley opened New England's largest snowtubing Park with four lifts, 16 lanes and over 600 snow tubes.

Instead of curling up on couch on a cold winter day, why not head outdoors, breathe in the fresh New England air and experience a new adventure. After all, the adventure of life is to learn. So what are you waiting for? Visit our website at www.merrimackvalley.org for details on snow packages and discount tubing tickets as well as take advantage of some of our overnight packages. We hope to see you on the slopes!



# ចូលឆ្នាំចិននៅឡូវែល



លោក ងោ គីមឈាង(រូបខាងឆ្វេងបង្អស់)និងក្រុមគ្រួសារ មិត្តភ័ក្តិ រីករាយបុណ្យចូលឆ្នាំចិន

**ដោយខ្មែរផុស.ស.រ.អា.**

ថ្ងៃទី៦កុម្ភៈ កន្លងទៅ នៅសាលភោជនីយដ្ឋាន "សំពៅមាស"ឡូវែលមានការរៀបចំពិធីចូលឆ្នាំចិនដោយលោក ង៉ោ គិមឈៀង នឹងក្រុមគ្រួសារសម្រាប់សហគមន៍"ខ្មែរកូនចៅវប្បធមិចិន"ដែលមករកនៅតំបន់ឡូវែលនឹងជុំវិញ។ ភ្ញៀវប្រមាន៤០០នាក់ ភាគច្រើនមានសំពត់អាវពណ៌ក្រហមជាសញ្ញានៃពិធីអឹកធឹកក្នុងភាពរីករាយរបស់វប្បធមិចិនបានមកជួបជុំមិត្តភ័ក្រ្តជប់លៀងភោជនាហារក្នុងហាងដែលឥឡូវប្តូរសោភ័ណ្ឌភាពតាំងលំអរទទួលភ្ញៀវយ៉ាងសមរម្យដោយតុកៅអី"ផ្ទុះ"ជាមួយគ្នាថែមទៀត។ នេះគឺជាការចាប់ផ្តើមពិធីដែលការលោត"ម៉ុងសាយ"បានផ្តល់អត្ថន័យគ្រប់គ្រាន់ដល់ការជួបជុំជប់លៀងគ្នានារាត្រីចូលឆ្នាំចិននោះ។

មិនត្រឹមតែប៉ុណ្ណោះមានការបង្ហាញនូវកម្មវិធីបវរកញ្ញាចូលរួមដោយកញ្ញាខ្មែរស្រស់ស្អាត។ប្រមាណ១០រូប ក្នុងសំពត់អាវសេរីនឹងមានវប្បធមិមានខ្មែរចិនជាដើមដឹកនាំមកបង្ហាញជូនដោយនាង សូផាលីណា នៅ"លីន"។

នៅពេលពេលឡើងមកលើឆាកជាកិត្តិយសដែលមានលោករីទ្ធី អ៊ុង លោក រ៉ាឌី ម៉ម លោក







ដាក់កម្រាលសស្គុះចងបូរពណ៌ក្រហមរំលេចទំនៀមទំលាប់ចិន។

គ្មានសុន្ទរកថា គ្មានភ្ញៀវកិត្តិយសដូចសព្វមួយដងភ្ញៀវចូលមកពេញសាលនៅម៉ោង៧កន្លះដោយមិនភ្លេចទៅថតរូបនៅក្លោងទ្វារកិត្តិយសមួយមានសរសេរអក្សរចិនទំនងជាការជូនពរជ័យនាឱកាស"ចូលឆ្នាំរក" គ្រប់ៗគ្នាមុននឹងទៅកាន់កន្លែងអង្គុយរៀងៗខ្លួន។ ម៉ោង៨គត់ សួរ "ម៉ុងសាយ"បានលាន់ឮយ៉ាងរន្ថើននាំតោ២សិប្បនិ្មតនៃវប្បធមិចិនមកលោករេរាំតាមបញ្ជាកុមារចិនម្នាក់នៅកណ្តាលឆាក នាំមកនៅការរីករាយក្អាកក្អាយនៃទំនៀមទំលាប់ពាន់ឆ្នាំដែលមិនបានបោះបង់ជាមួយនឹងអ្នកដែលមានខ្សែស្រឡាយ-ឬឈាមជ័រជាចិន។ តោសិប្បនិមិត្តបានលោតទៅគួរសមពីតុមួយទៅតុមួយលោតទៅខាំយកស្រោម "កញ្ចប់ក្រហម"ពីដៃភ្ញៀវដែលមកពីជិតឆ្ងាយយ៉ាងប៉ិនប្រសព្វទំនងជាពីធីនៃប្រសិទ្ធិពរចំរុងចំរើនដល់គ្រួសារខ្មែរនិមួយៗឱ្យជួបប្រទះនឹងដំណើរជីវិត "ហេង។"ជាដ៏រាបដែលជាធម្មតាគេតែងអុចផាវរ៉េតនី អេលីយ៉ុត នាចន្លោះកម្មវិធីកម្មវិធីភ្លេងនឹងចម្រៀងសម័យខ្មែរលោក ង៉ោ គិមឈៀង ទោះបីជាសមាជិសភាខ្មែរខាងគណបក្សសង្គ្រោះជាតិក៏ដោយលោកបានកែរតម្រូវពាក្យដែលថាពិធីនៃគណបក្សសង្គ្រោះជាតិមកជា "ពិធីរបស់ខ្មែរ"ទាំងអស់គ្នាទៅវិញ ហើយសម្តែងការអរគុណភ្ញៀវដែលសុទ្ធតែជាមិត្តភ័ក្រ្តបានមកចូលរួមយ៉ាងកុះករនារាត្រីនេះ។ លោកបានធ្វើការអំពាវនាវបន្ថែមពីការធ្វើពិធី"លក់ឆ្នោតវត្ថុ" ថាយកប្រាក់ចំណេញនេះ ទៅទិញអាវឃោសនាសម្រាប់ខេត្តកំពុងឆ្នាំងជាមណ្ឌលដែលលោកបានជាប់ឆ្នោត។

ភ្ញៀវដ៏ច្រើនកុះករនេះ បញ្ជាក់ថា សហគមន៍ខ្មែរសម្បូរដោយ"កូនចៅចិន"ដែលនៅរក្សាទំនៀមទំលាប់ដូនតាមិនឱ្យដាច់។ គ្រួសារចិនមានការគ្រប់គ្រងកូនចៅសែស្រឡាយប្រកបដោយក្បួនច្បាប់ជាក់លាក់ដូចជា: សែនកុងម៉ា ពីធីមង្គលការ របៀបគោរពប្តីប្រពន្ធ របៀបអប់រំកូនចៅ-គោរពម្តាយឪពុក ពិធីសម្រាប់អ្នកស្លាប់... ក្បួនតម្រាទាំងនេះបានជួយកូនចៅចិនច្រើនណាស់ក្នុងការ"រកស៊ី"ជាពិសេសហើយសំខាន់ទៅទៀតនោះ គឺនៅពេលមានជីវភាពលំបាកលំបិនតែក្នុងនោះមិនមានល្បិចដូចរឿង"សាមកុក"ដ៏ល្បីល្បាញនោះទេ។ ចំណែកឯខ្មែរវិញ មានទំនៀមទំលាប់ជា"ក្បួនខ្នាត"មិនឆ្ងាយពីចិនទេ តែចាប់តាំងពីស្រុកទេសមានកលិយុគពីសតវត្សទី១៥មកមានសង្គ្រាមមិនចេះឈប់ឈរខ្សត់ខ្សោយស្មារតីប្រកាន់យកការ"គេចពីការសម្លាប់"ជាមូលដ្ឋាន... ម្ល៉ោះហើយតំរូវធ្វើដូម្តេចឱ្យតែបានរួចជីវិត។ មូលដ្ឋានអប់រំនាពេលនោះ បានក្លាយទៅជាទំនៀមទំលាប់ថ្មីរបស់ខ្មែរ ដូចជា"ត្រង់ស្លូតស្លាប់វៀចវេមានភ័ព្វ អាយុយឺនយូរ"ឬក៏"ផ្លូវវៀចកុំបោះបង់ផ្លូវត្រង់កុំដើរហោង" ឬក៏"ចង់ចេះឱ្យសម្លាប់អាចារ្យ"... នៅមានច្រើនទៀត ដែលល្បីល្បាញដូចគ្នាក្នុងសង្គមខ្មែរ។ សំណាងដែរដែលវប្បធមិចិននឹងខ្មែរអាចរួមប្រសព្វគ្នាបានមានការរលាយចូលគ្នាច្រើនកន្លែង ថ្វីត្បិតតែសាស្រ្តខុសគ្នាតែជាមួយយួនមិនសូវស៊ីគ្នាទេ ធ្វើឱ្យខ្មែរជំនាន់ក្រោយៗប្រកាន់វប្បធមិ"បុរាណកូនចៅចិន"មានមាយាទច្រើនជាងកូនចៅ"សាមកុក" ដែលជាវប្បធមិអ្នកចម្បាំងយក"ឈ្នះ"ជាមូលដ្ឋាន។

ខ្មែរកូនចៅចិន គឺជាខ្មែរដូចគ្នានឹងខ្មែរកូនចៅខ្មែរដែរ គ្មានទំនាស់នឹងគ្នាទេ នៅស្រុកខ្មែរគេចូលឆ្នាំចិនផង ចូលឆ្នាំខ្មែរទៀត តែថ្ងៃដើមឆ្នាំដូចគ្នាក្នុងប្រក្រតីទិន"ចន្រ្ទគតិ" ជារៀងរហូតមក។

កម្មវិធីរាត្រីចូលឆ្នាំចិននៅឡូវែលមកដល់ពាក់កណ្តាលអាធ្រាតហើយ នៅតែមិនចង់ចប់ដោយបរយាកាសសែនរីករាយ ៕

**"សួស្តីឆ្នាំវក២៥៦០ព.ស. សូមឱ្យលោកអ្នករកស៊ីមានបាន"**









# ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

ព្រះសង្ឃជាមួយនឹងវត្ថុប្រើប្រាស់សម័យទំនើប

សម័យពុទ្ធកាលជាង២៥០០ឆ្នាំមុន វត្ថុវិទ្យាសាស្ត្រមិនទាន់ចំរើនលូតលាស់នៅឡើយ ដូច្នេះការបញ្ញត្តសិក្ខាបទតូចតាចខ្លះរបស់ព្រះពុទ្ធចំពោះព្រះសង្ឃ ស្របទៅតាមសម័យនោះ វៀរលែងតែសិក្ខាបទដែលប្រព្រឹត្តនាំឲ្យត្រូវអាបត្តិធ្ងន់ដូចអាបត្តិបារាជិក អាបត្តិសង្ឃាទិសេសជាដើម សម័យណាក៏ត្រូវបញ្ញត្តិដូចគ្នា។ សម័យមុន វិទ្យុ ទូរទស្សន៍ ទូរស័ព្ទ ទូរសារ ឧបករណ៍ផលិតក្រដាសផលិតសៀវភៅ យន្តយានធ្វើដំណើរគ្រប់ប្រភេទជាដើមមិនទាន់កើតមាននៅឡើយ។ សម័យទំនើបនេះ មានវត្ថុទាំងនេះបានកើតឡើង ព្រះសង្ឃក៏យកវត្ថុតាំងនេះមកប្រើប្រាស់ដើម្បីអភិវឌ្ឍន៍ព្រះពុទ្ធសាសនា។ សម័យមុន សូម្បីតែស្លាបព្រាក៏គ្មានដែរ ព្រះសង្ឃឆាន់ចង្ហាន់ដោយព្រះហស្ត(ដៃ)។

អ្នករិះគន់ព្រះសង្ឃដោយមិនសមហេតុផលមិនស្របតាមព្រះធម៌ ដូចប្រើពាក្យថា ព្រះសង្ឃនិងគ្រហស្ថដូចតែគ្នា កិលេសនៅនឹងគ្រលៀន។ ត្រង់នេះ សូមអ្នករិះគន់សិក្សាយល់ព្រះពុទ្ធសាសនាឲ្យបានច្បាស់លាស់ ព្រះអរហន្តដែលបានសម្រេចជាព្រះអរហត្ត លះបង់កិលេសតណ្ហាអស់ហើយ គឺលះបង់នូវកិលេសតណ្ហាក្នុងផ្លូវចិត្ត ពុំមែនលះផ្លូវកាយទេ កាយមានភាពជាអព្យាកតធម៌ បុណ្យបាបនៅលើផ្លូវចិត្ត ពុំស្ថិតនៅលើផ្លូវកាយទេ។ បើកិលេសតណ្ហាស្ថិតនៅលើកាយដូចអ្នករិះគន់ថាមែន ការបានសម្រេចជាព្រះអរហន្តមិនបាច់អប់រំចិត្តតាមផ្លូវសមថវិបស្សនាធ្វើអ្វីទេ ត្រូវសម្លាប់ខ្លួនស្លាប់ទាំងគ្រលៀនផង បានជាព្រះអរហត្តហើយ នេះជាពាក្យមួលបង្កាច់ព្រះពុទ្ធដីកា។ បាតុភូតដែលកើតមានតាមផ្លូវកាយ កើតមានជាធម្មតាតាមច្បាប់ធម្មជាតិ ទាំងសម្មតិសង្ឃទាំងព្រះអរហន្ត ប៉ុន្តែលោកសង្រួមសង្កត់ផ្លូវចិត្តមិនត្រេតអរ ដោយពិចារណាថា វេទនាជាសុខក្តីជាទុក្ខក្តី ពុំមែនជាសត្វជាបុគ្គលមានសភាពសោះសូន្យទទេ។

អ្នកបួសដែលហៅថា ឧត្តមភេទ មានលក្ខណៈខុសគ្នាពីគ្រហស្ថ ព្រោះលោកលះបង់នូវជីវភាពជាគ្រហស្ថជាហីនភេទ ចេញចាកកាមមករស់នៅក្នុងទីមួយដែលហៅថាវត្ត នេះជាចម្លើយឆ្លើយទៅអ្នករិះគន់ថា ព្រះសង្ឃនិងគ្រហស្ថដូចគ្នា។ ទាយជ្ជបរិភោគ ក្នុងបរិភោគ៤យ៉ាង ព្រះពុទ្ធសំដែងថា ព្រះសង្ឃគួរទទួលនូវមត៌ក គឺបច្ច័យ៤ដែលគ្រហស្ថប្រគេនដោយសទ្ធា គួរទទួលការថ្វាយបង្គំដូចក្នុងសង្ឃគុណ ព្រោះជាអ្នកមានសីល៕

វត្តខ្មែរកាណាដា,ថ្ងៃ១៥កុម្ភ២០១៦;www.hoksavann.org;savannhok@yahoo.com




តមកពីទំព័រទី ០៦

## អង្គការ "ធ្វើ-វា-ដោយខ្លួនឯង"...

មិនគិតថ្លៃ ប៉ុន្តែសំរាប់ប្រជាជនទូរទៅ គឺគិតតំលៃ៥ដុល្លារ ។ ហើយជាពិសេសនោះ គំរូភីស្សារបារប្រាក់នឹងកន្លែងដាច់ដោយឡែកពីអ្នកកាសែតក៏ត្រូវគេបានដាក់រួមបញ្ចូលក្នុងកម្មវិធីនេះដែរ ។ មិន ថាចាស់ ឬក៏ក្មេងពួកគេរីករាយនឹងទទួលស្វាគមន៍ជានិច្ច ។

**អំពី DIY Lowell "ធ្វើ-វា-ដោយខ្លួនឯង របស់ទីក្រុងឡូវែល** **តទៅទំព័រទី១១**

គឺជាអង្គការប្រជាជនមិនជាផ្លូវការមួយដែលតែងតែព្យាយាមជួយអ្នកជិតខាង ដើម្បីបង្កើតនូវព្រឹត្តិការណ៍ ឬក៏គំរោងជាលក្ខណៈទ្រង់ទ្រាយតូចឱ្យកើតឡើងនៅពេលតែមួយ ។ អង្គការនេះទទួលការគាំទ្រពីក្រុមប្រឹក្សាវប្បធម៌ក្រុងឡូវែល ហើយនឹងភ្នាក់ងារក្នុងតំបន់ដែលភ្នាក់ងារនេះក៏ទទួលបានគាំទ្របន្តពីភ្នាក់ងាររដ្ឋក្រុមប្រឹក្សាវប្បធម៌របស់ម៉ាសាឈូសេត ។ ខ្លួនក៏កំពុងប្រមូលនូវគំនិតថ្មីនៅលើគេហទំព័ររបស់ខ្លួន និងបើសិនជាចង់បញ្ចេញគំនិត ឬក៏ស្វែងយល់បន្ថែមទៀតពីអង្គការនេះ សូមចូលទៅគេហទំព័រ DIY Lowell.org ។

ទំនាក់ទំនងសហស្ថាបនិក អូរូរ៉ា អេរិកសុន (Aurora Erickson) នឹង គ្រីស ហេយ (Chris Hayes)

លេខទូរស័ព្ទ 217 493 5293 ឬ 217 722 9516

អ៊ីមែល info@dilylowell.org

Continued from page 06

## Minister Backs Legal ...

source of fruit tree saplings to plant in a public location, and began discussions to install cabinets to share free books at bus stops. DIY Lowell leaders also organized a project to work with small businesses and property owners to decorate downtown Lowell storefronts last November. DIY Lowell groups are entirely volunteer-led and learn from local institutions, community leaders, and one another.

"We're especially proud of the fact that many of the volunteers had never done anything like fundraising, running meetings, or securing approvals before, and now they're feeling empowered to do more in the future," added Erickson.

The event will be free for DIY Lowell volunteers and $5 at the door for the general public. Media/press passes are available. Pizza samples from UnchARTed are included, cash bar available. All ages are welcome.

About DIY Lowell: Do-it-Yourself Lowell is an informal citizen organization dedicated to help neighbors make small-scale events and projects happen together. It is supported in part by a grant from the Lowell Cultural Council, a local agency which is supported by the Massachusetts Cultural Council, a state agency. The organization collects ideas on their website, and to submit an idea or learn more, visit DIYLowell.org.

Contact: Aurora Erickson and Chris Hayes, Co-Founders

Phone: (217)493-5293 or (217)722-9516

Email: info@diylowell.org

តមកពីទំព័រទី ០៣

## ក្រុមមេដឹកនាំផ្តាច់ការមកកាលីហ្វ័រនីញ៉ា

ង្វៀង ភូត្រុង នៅកាន់អំណាចជានាយករដ្ឋមន្ត្រីជាង២អាណត្តិ៥ឆ្នាំម្តងល្បីឈ្មោះខាងពាណិជ្ជកម្មនឹងជាមិត្តរបស់សហរដ្ឋអាមេរិក ឌុង ក៏ល្បីឈ្មោះពីការដាក់គំនាបសង្កត់លើមិត្តភាពខ្មែរនឹងឡាវណាស់ដែរ ។

**បាតុកម្មនៅខាងក្រៅប្រជុំ "យូអេស-អាស៊ានស៊ុបមីត"**

សកហាគមន៍ខ្មែរ "សម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំង" នៅសហរដ្ឋអាមេរិកបានបាននាំគ្នាចូលរួមធ្វើបាតុកម្មប្រឆាំងនឹងវត្តមានមេផ្តាច់ការនិយមទាំងនោះ ជាពិសេសប្រឆាំងនឹងវត្តមាននាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកំពុងអភិវឌ្ឍន៍នយោបាយហឹង្សាពុករលួយបំផ្លាញសម្បត្តិជាតិលើប្រជាពលរដ្ឋខ្លួនឯង ។ ថ្វីត្បិតតែមានអ្នកគាំទ្រច្រើននៅស.រ.អា. នេះ សម រង្ស៊ី មេគណបក្សសង្គ្រោះជាតិនិរទ្ទេសខ្លួនឯងនៅក្រៅប្រទេសបានប្រកាសអញ្ជើញក្រុមគាំទ្ររបស់ខ្លួន "កុំឱ្យចូលរួម" ដោយបារម្ភខ្លាចពីការសងសឹកហឹង្សារបស់ ហ៊ុន សែន ទៅលើសមាជិករបស់ខ្លួននៅឯស្រុកខ្មែរ -កាលពីខែតុលាឆ្នាំមុន ហ៊ុន សែន បានធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសបារាំងបាតុកម្មមួយរបស់សហគមន៍ខ្មែរនៅទីនោះបានកើតឡើងនៅទីក្រុងប៉ារីស នាពេលនោះ -ហ៊ុន សែន បានបញ្ជាក្រុមអង្គរក្សរបស់ខ្លួនឱ្យធ្វើបាតុកម្មសងសឹកនៅឯភ្នំពេញបណ្តាលឱ្យសមាជិកសភាជាតិខាងគណបក្សសង្គ្រោះជាតិ ២រូបមានរបួសជាទម្ងន់ ។

ទោះជាយ៉ាងនេះក្តីសម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំង ដែលជាអង្គការឯករាជ្យ មិនបានស្តាប់ឱវាតរបស់ សម រង្ស៊ី ទេ នឹងក៏មិនបញ្ឈប់បាតុកម្មរបស់ខ្លួនដែរ ។ ថ្ងៃទី១៥កុម្ភៈ នេះ សហគមន៍ខ្មែរប្រមាណ ៥-៧០០នាក់ មកពីគ្រប់តំបន់ជុំវិញសហរដ្ឋបានទៅចូលរួមធ្វើបាតុកម្មជាមួយសហគមន៍អាស៊ីឯទៀត១ មានទាំងអស់ប្រមាណជា២ពាន់នាក់ ដែលមកសម្តែងមតិប្រឆាំងនឹងវត្តមានមេដឹកនាំផ្តាច់ការនៃប្រទេសវៀង១ខ្លួនដែលមកប្រជុំនៅរដ្ឋកាលីហ្វ័រញ៉ាខាងត្បូង ៕

# ពលរដ្ឋខ្មែរនៅទីក្រុងឡូវែលទាមទារឱ្យក្រសួងធម្មការ ផ្សឹកភិក្ខុសង្ឃ ញ៉ែម គឹមតេង

**ដោយ: សីរី មុនី**

ប្រជាពលរដ្ឋប្រមាណជាង៣០០នាក់នៅទីក្រុងឡូវែល (Lowell) សហរដ្ឋអាមេរិក ទាមទារឱ្យក្រសួងធម្មការ និងសាសនា ផ្សឹកព្រះភិក្ខុសង្ឃ ញ៉ែម គឹមតេង ចេញពីព្រះពុទ្ធសាសនា។ ពលរដ្ឋទាំងនោះអះអាងថា ភិក្ខុសង្ឃអង្គនេះប្រព្រឹត្តខុសវិន័យព្រះពុទ្ធសាសនាធ្ងន់ធ្ងរ មិនគួរបន្តបង់ស្បង់ចីវរជាសង្ឃបន្តទៀតនោះទេ។

ទាក់ទិននឹងការចោទប្រកាន់នេះ ក្រសួងធម្មការ និងសាសនា ធ្លាប់ទទួលស្គាល់ថា ព្រះភិក្ខុសង្ឃ ញ៉ែម គឹមតេង ពិតជាបានប្រព្រឹត្តអំពើអាសអាភាសខុសនឹងវិន័យពុទ្ធសាសនាពិតប្រាកដមែន។

ប្រជាពលរដ្ឋប្រមាណជាង៣០០នាក់ (៣៥២នាក់) នៅទីក្រុងឡូវែល រដ្ឋម៉ាសាឈូសិត (Massachusetts) សហរដ្ឋអាមេរិកនៅតែបន្តទាមទារឱ្យក្រសួងធម្មការ ចាប់ព្រះសង្ឃ ញ៉ែម គឹមតេង ផ្សឹកដោយចោទថា បានសេពមេថុនធម្ម (រួមភេទ) ជាមួយស្ត្រីម្នាក់ក្នុងវត្តដែលខុសនឹងវិន័យពុទ្ធបញ្ញត្តិ។

តំណាងប្រជាពលរដ្ឋនៅទីក្រុងឡូវែល៤នាក់ រួមមានលោក មាស សេម លោក ខឹម ច័ន្ទថា មុំ រ៉ាឌី និងលោក យន សុវណ្ណ បានប្តឹងភិក្ខុសង្ឃ ញ៉ែម គឹមតេង ទៅអាជ្ញាធរកម្ពុជា ដើម្បីឱ្យចាប់ផ្សឹកចេញពីព្រះពុទ្ធសាសនា ក្នុងន័យជៀសវាងកុំឱ្យភិក្ខុអង្គនេះបន្តប្រព្រឹត្តខុសធម៌វិន័យ និងយកព្រះពុទ្ធសាសនាធ្វើជាខែលសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនជាបន្តទៀត។ លោក ខឹម ច័ន្ទថា និយាយថា ព្រះសង្ឃអង្គនេះប្រព្រឹត្តខុសវិន័យពុទ្ធសាសនាយូរណាស់មកហើយ ប៉ុន្តែក្រសួងធម្មការ និងសាសនាមិនទាន់ចាប់ផ្សឹកនៅឡើយទេ: "លោកហ្នឹងធ្លាប់និយាយថា គ្មាននរណាអាចធ្វើអីគាត់កើតទេ។ ខ្ញុំសូមសំណូមពរដល់ប្រមុខរដ្ឋាភិបាលកម្ពុជាសម្តេចនាយក ហ៊ុន សែន មេត្តាពិនិត្យនិងមើលរឿងហ្នឹងតាមរយៈវិទ្យុអាស៊ីសេរី។ ខ្ញុំសូមផ្តាំក្នុងនាមប្រជាពលរដ្ឋដែលគោរពព្រះពុទ្ធសាសនា មិនគួរឱ្យបុគ្គលម្នាក់មកបំផ្លាញសាសនារបស់រដ្ឋទាំងមូល មិនមែនតែប្រជាពលរដ្ឋនោះទេ គឺឱ្យតែអ្នកកាន់ពុទ្ធសាសនា គេស្អប់ខ្ពើមអំពើលាមក ព្រោះអីស្ថាប័នក្រោមមិនហ៊ានធ្វើរឿងហ្នឹង"។

លោកបន្តថា ប្រជាពលរដ្ឋនៅទីក្រុងឡូវែលសហរដ្ឋអាមេរិកមិនចង់ទាមទារអ្វីផ្សេងនោះទេ គឺគ្រាន់តែចង់ឱ្យក្រសួងធម្មការ និងសាសនាចាប់ភិក្ខុសង្ឃនោះផ្សឹកចេញពីព្រះពុទ្ធសាសនា។ ពលរដ្ឋនៅទីក្រុងឡូវែលបានចោទប្រកាន់ភិក្ខុសង្ឃអង្គនេះតាំងពីឆ្នាំ២០១៣។



ញ៉ែម គឹមតេង

វិទ្យុអាស៊ីសេរីមិនទាន់អាចទាក់ទងសុំការឆ្លើយតបពីភិក្ខុសង្ឃ ញ៉ែម គឹមតេង បាននៅឡើយទេនៅថ្ងៃទី៧ កុម្ភៈ នេះ។

ទោះបីជាយ៉ាងណាក៏ដោយ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ព្រះតេជព្រះគុណ ញ៉ែម គឹមតេង បានសរសេរលិខិតបង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក (Facebook) របស់ព្រះអង្គ ដោយបដិសេធថា ព្រះតេជព្រះគុណមិនបានប្រព្រឹត្តខុសវិន័យព្រះពុទ្ធសាសនាដូចការចោទប្រកាន់របស់ប្រជាពុទ្ធបរិស័ទទាំង៣៥២នាក់នៅទីក្រុងឡូវែលនោះទេ។

កំណត់ហេតុអង្គប្រជុំស្តីពីករណីប្រព្រឹត្តអនាចារអាសអាភាសរបស់ព្រះតេជព្រះគុណ ញ៉ែម គឹមតេង នៅក្នុងវត្តត្រៃរតនារាម ក្រុងឡូវែល រដ្ឋម៉ាសាឈូសិត សហរដ្ឋអាមេរិក កាលពីខែវិច្ឆិកា ឆ្នាំ២០១៣ ដែលមានសមាសភាពចូលរួមប្រជុំ គឺមានសម្តេចព្រះវន្ន័ត ណយ ច្រឹក ព្រះញាណវង្ស ឃឹម សន ព្រះសិរីសម្មតិវង្ស លន់ សុគន្ធា រដ្ឋមន្ត្រីក្រសួងធម្មការ លោក មិន ឃិន អ្នកនាំពាក្យក្រសួងធម្មការលោក សេង សុមុនី និងលេខាកត់ត្រាលោក សោម រតនា បានចុះហត្ថលេខាបញ្ជាក់ថា វីដេអូដែលថតបានសកម្មភាពប្រព្រឹត្តអំពើអាសអាភាសនោះ គឺពិតជារូបភិក្ខុសង្ឃ ញ៉ែម គឹមតេង ពិតប្រាកដមែន។

ក្នុងលិខិតនោះបញ្ជាក់ទៀតថា អង្គប្រជុំបានឯកភាពគ្នាព្យួតួនាទីទាំងអស់របស់ព្រះតេជព្រះគុណ ញ៉ែម គឹមតេង ប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និងអគាធិការដ្ឋានពុទ្ធិកសិក្សាជាតិជាបណ្តោះអាសន្នបង្កើតគណៈកម្មការចម្រុះរវាងក្រសួងធម្មការ និងសាសនា គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងថេរសភាសង្ឃដើម្បីស៊ើបអង្កេត សិក្សាស្រាវជ្រាវក្នុងគោលដៅអនុវត្តទៅតាមវិន័យព្រះពុទ្ធសាសនាឱ្យបានឆាប់រហ័ស។ ទោះបីជាការសរសេរជាលាយលក្ខណ៍អក្សរថា នឹងដោះស្រាយជុំវិញករណីនេះក៏ដោយ ប៉ុន្តែរហូតមកដល់នឹងពេលនេះ ក្រសួងធម្មការ និងសាសនា មិនមានចំណាត់ការណាមួយជាក់លាក់ចំពោះភិក្ខុសង្ឃ ញ៉ែម គឹមតេង នៅឡើយទេ។

តំណាងប្រជាពលរដ្ឋនៅទីក្រុងឡូវែលអះអាងថា ព្រះភិក្ខុសង្ឃ មួង រ៉ា ព្រះចៅអធិការវត្តមុនីប្រសិទ្ធិវង្សហៅវត្តព្រែកព្នៅ និងជាអគាធិការរងនៃអគាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ធ្លាប់សន្យាថានឹងចាប់ភិក្ខុសង្ឃ ញ៉ែម គឹមតេង ផ្សឹកមកជាគ្រហស្ថធម្មតាភ្លាមនៅពេលភិក្ខុអង្គនេះនិមន្តមកដល់ទឹកដីកម្ពុជា។

បច្ចុប្បន្នភិក្ខុសង្ឃ ញ៉ែម គឹមតេង និមន្តមកដល់កម្ពុជាជាង១ខែហើយ។ ភិក្ខុសង្ឃនេះបើតាមការបង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុករបស់ព្រះអង្គ គឺព្រះអង្គគង់នៅវត្តមហាមន្ត្រី កុដិលេខ២៤ក្រុងភ្នំពេញ។

វិទ្យុអាស៊ីសេរីមិនទាន់អាចសុំការពន្យល់ពីព្រះភិក្ខុសង្ឃ មួង រ៉ា ព្រះចៅអធិការវត្តមុនីប្រសិទ្ធិវង្ស ហៅវត្តព្រែកព្នៅ និងលោក មិន ឃិន រដ្ឋមន្ត្រីក្រសួងធម្មការបាននៅឡើយទេ នៅថ្ងៃទី៧ កុម្ភៈ។

វិន័យព្រះពុទ្ធសាសនាភិក្ខុសង្ឃអង្គណាដែលបានសេពមេថុនធម្ម (រួមភេទ) ជាមួយស្ត្រី និងញ៉ាំងឱ្យចេញទឹកកាមនោះ គឺត្រូវអាបត្តិបារាជិក។

សមណនិស្សិតផ្នែកទស្សនវិជ្ជាពុទ្ធសាសនាព្រះតេជព្រះគុណ ផល្លា មានថេរដីកាថា ភិក្ខុសង្ឃដែលរួមភេទជាមួយស្ត្រីហើយ មិនត្រូវបានអនុញ្ញាតឱ្យបួសក្នុងសំណាក់សាសនាព្រះពុទ្ធនោះឡើយ: "ភិក្ខុសង្ឃដែលត្រូវអាបត្តិបារាជិកនេះលោកអត់មានអីត្រូវធ្វើទេ លោកប្រៀបបាននឹងដើមត្នោតកំបុតចុងអីចឹង។ នៅពេលដែលត្រូវហើយ ចាំបាច់ភិក្ខុនោះត្រូវតែសឹកចេញនៅអាចនៅជាសង្ឃបានទេ"។

ប្រជាពលរដ្ឋជាង៣០០នាក់នៅទីក្រុងឡូវែល រដ្ឋម៉ាសាឈូសិត សហរដ្ឋអាមេរិក ស្នើសុំឱ្យក្រសួងធម្មការ និងប្រមុខរដ្ឋាភិបាលកម្ពុជា លោក ហ៊ុន សែន ត្រូវចាត់វិធានការចំពោះភិក្ខុសង្ឃ ញ៉ែម គឹមតេង ជាបន្ទាន់ ដោយត្រូវចាប់ផ្សឹកពីភិក្ខុសង្ឃអង្គនេះមកជាគ្រហស្ថធម្មតា ដើម្បីជៀសវាងកុំឱ្យមានផលប៉ះពាល់ដល់ភិក្ខុសង្ឃដទៃផ្សេងទៀតក្នុងព្រះពុទ្ធសាសនា ព្រោះករណីនេះ បានកើតឡើងជាច្រើនឆ្នាំមកហើយ តែក្រសួងធម្មការមិនទាន់មានវិធានការណាមួយជាក់លាក់នៅឡើយនោះទេ។

កំណត់ចំណាំចំពោះអ្នកបញ្ចូលមតិនៅក្នុងអត្ថបទនេះ: ដើម្បីរក្សាសេចក្តីថ្លៃថ្នូរ យើងខ្ញុំនឹងផ្សាយតែមតិណា ដែលមិនជេរប្រមាថដល់អ្នកដទៃប៉ុណ្ណោះ៕

**កំណត់បន្ថែមរបស់ខ្មែរប៉ុស.ស.រ.អា.**

ថ្វីត្បិតតែរឿងអាម៉ាសរបស់សង្ឃ ញ៉ែម គឹមតេង មានភស្តុតាងនៅក្នុងខ្សែវីដេអូជាសាធារណប៉ុណ្ណោះទៅហើយក៏ដោយ ក៏ព្រះតេជគុណ សៅ យន ចៅអធិការវត្តខ្មែរឡូវែលនៅតែខិតខំការពារសង្ឃរូបនោះយ៉ាងពេញទំហឹង ថាជារឿងប្រឌិតកែរូបនៅក្នុងវីដេអូព្រមទាំងយកក្រុមជំនុំ"គណសង្ឃនៃសហគមន៍ព្រះសង្ឃខ្មែរអាមេរិក"មកជាកម្លាំងគាំទ្រកិច្ចការពារ ញ៉ែម គិមតេង ដោយសម្រេចថា ញ៉ែម គិមតេង មិនបានប្រព្រឹត្តអំពើអាណាចារនៅក្នុងវត្តនោះទេ។ បាតុកម្មពុទ្ធសាសនិក បានផ្ទុះផ្អើលពេញឡូវែលទាមទារឱ្យផ្សឹកសង្ឃនោះហើយបណ្តេញចេញពីវត្ត -ក្រសួងធម្មការនៅភ្នំពេញក៏បានដឹងពីរឿងនេះហើយចាត់វិធានការ ដកបណ្ណស័ក្តិនិងតួនាទីចេញ -ពិសេសទៅទៀតនោះ បណ្ឌិត ឥទ្ធិពលទើបនឹងសឹកចាកសិក្ខាបទម្នាក់ដែលជាមិត្តរបស់ ញ៉ែម គិមតេង បានដឹងរឿងនេះច្បាស់បានចេញអនុស្សាវរណពិសេសភ្លាមៗ ដើម្បីការពារវត្តខ្មែរឡូវែលឱ្យយោបល់ថា ១-ឱ្យ ញ៉ែម គិមតេង លាលែងពីគ្រប់ដំណែងក្នុងសហគមន៍ព្រះសង្ឃខ្មែរ ២-ឈប់បញ្ចេញមុខមាត់ក្នុងស្បង់ចីវរ ៣-ឈប់ធ្វើលិខិតបន្ទំបំភ័ន្តមហាជនតទៅទៀត ៤-ត្រឡប់ទៅកម្ពុជាប្រឈមមុខនឹងគណៈតុលាការសង្ឃក្នុងរឿងរួមភេទក្នុងកុដិ ៥-បើចង់នៅអាមេរិកគប្បីលាចាកសិក្ខាបទ រៀបការនឹងដៃគូរបស់ខ្លួនជាមួយគ្នាស្របច្បាប់។ តែ ញ៉ែម គិមតេង មិនបានទទួលតាមឱវាទនោះទេទៅបញ្ចេញមុខមាត់តាមកញ្ចក់ទូរទស្សន៍"អិលធីស៊ី"រាល់អាទិត្យក្នុងនាមវត្តព្រះតេជគុណ សៅ យន ធ្វើឱ្យសហគមន៍ព្រះពុទ្ធសាសនានៅឡូវែលទទួលភាពអាម៉ាសពីវត្តមួយនេះគ្រប់គ្នា៕

# ល្បែងរង់ចាំ

**ដោយ Kayla Chan បកប្រែដោយ តារាយុទ្ធ ហង្ស**


Kayla Chan

នៅឆ្នាំនេះ ស៊ីនា Seniors (សិស្សសាលាទី១២) គួរតែបានដាក់ពាក្យប្រលងចូលមហាវិទ្យាល័យរួចរាល់ហើយ។ អ្នកខ្លះប្រហែលជាបានដឹងដំណឹងពីសាលាដែលគេបានដាក់ពាក្យ ប្រសិនបើពួកគេបានដាក់ពាក្យសុំចូលសាលាប្រញាប់មុនគេ។ ថ្វីបើភាពតានតឹងនៃការដាក់ពាក្យសុំចូលរៀនត្រូវបានបញ្ចប់ ប៉ុន្តែនៅមាននូវភាពតានតឹងមួយទៀតក្នុងចំណោមសិស្សសាលាដែលមានឈ្មោះថា ការរងចាំនៃលទ្ធផល។ ស៊ីនាតែងប្រញាប់ប្រញាល់ទៅផ្ទះដើម្បីឆែកនៅប្រអប់សំបុត្ររបស់ពួកគេថាតើមានសំបុត្រមកពីសាលាថា ទទួលឱ្យពួកគេចូលរៀនដែររឺទេ?

ពេលខ្លះពេលឮដំណឹងមកពីសាកលវិទ្យាល័យអាចផ្លាស់ប្តូរអារម្មណ៏របស់សិស្សដែលអាក់អន់ចិត្តទៅសប្បាយ ឬក៏ច្រណែន។ សូមមេត្តាកុំអាក់អន់ស្រពុនចិត្ត ប្រសិនបើអ្នកមិនបានទទួលអ្វីដែលអ្នកចង់បាន ឬក៏ការដែលអ្នកដាក់ពាក្យសុំចូលរៀនលើកតំបូងមិនបានជោគជ័យ។ ជួនកាលអ្នកខ្លាំងទើបអាចសំរេចរឿងខ្លះបាន។ ខ្ញុំជាសិស្សម្នាក់នៅឯសាកលវិទ្យាល័យ ម៉ាសាឈូសេត (Umass Lowell) ប៉ុន្តែវាក៏ជាសាលាចុងក្រោយដែរ ដែលខ្ញុំចង់រៀន។ ចាប់តាំងពីផ្តើមរហូតដល់ពេលដែលខ្ញុំបានចូលកម្មវិធីថ្ងៃទទួលសិស្សថ្មីឱ្យចូលរៀន (Accepted Student’s Day) ខ្ញុំបានដឹងថាខ្ញុំបានមកដល់ទីនេះ។ ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលខ្ញុំបានចូលរៀននៅសាលាមួយនេះ ពីព្រោះសាលានេះបានជួយពង្រឹងខ្ញុំទាំងការសិក្សានឹងរឿងផ្ទាល់ខ្លួន ហើយសាលាក៏បានផ្តល់នូវឱ្យកាសដ៏អស្ចារ្យជាច្រើនមកឱ្យខ្ញុំ។ នៅពេលនេះ ជួនកាលពួកយើងមិនដឹងថា ហេតុអ្វីបានជាជីវិតនាំយើងឱ្យដើរផ្លូវបែបនេះ ប៉ុន្តែយើងគ្រាន់តែជឿជាក់ថា ជីវិតនឹងនាំអ្នកទៅកន្លែងដែលអ្នកគួរតែទៅ។ ថ្វីបើយោបល់នេះ ប្រហែលជាអ្នកមិនទាន់អាចទទួលបានតែអ្នកអាចតែងតែផ្លាស់ប្តូរសាលាបាន។

នៅពេលតែមួយនេះដែរ អ្នកប្រហែលនឹងច្រណែនមិត្តភក្តិរបស់អ្នកនឹងសិស្សដែលបានចូលរៀន ឬក៏ជ្រើសរើសមុខវិទ្យាដ៏ច្បាស់លាស់មួយនៅឯសាលកលវិទ្យាល័យ ឬក៏ច្រណែននឹងពួកគេដែលទទួលបានជំនួយផ្នែកហិរញ្ញវត្ថុច្រើនជាងអ្នក។ ប៉ុន្តែការច្រណែននឹងមិនផ្លាស់ប្តូររឿងដែលបានកើតឡើងហើយទេ ផ្ទុយទៅវិញប្រសិនជាអ្នកធ្វើជាអ្នកគាំទ្ររបស់ពួកគេវិញនោះវានឹងឆ្លុះបញ្ចាំងអំពីលក្ខណះសម្បត្តិរបស់អ្នកជាជាងសាលាដែលអ្នករៀន។

មានរឿង ២ ទៅ ៣យ៉ាងដែលអ្នកគួរតែចាំ។ ទីមួយ ប្រកត់ថា អ្នកបានដឹងអំពីផ្នែកហិរញ្ញវត្ថុនឹងចំនួនជំនួយរបស់សាលាដែលអ្នកបានទទួលហើយនឹងយកនូវជំនួយនោះដើម្បីប្រៀបធៀបជាមួយនូវជំរើសរបស់អ្នក។ ប្រសិនជាអ្នកមិនប្រកត់អំពីកត្តាណាមួយនៃអាហារូបករណ៏ ឬក៏ជំនួយផ្នែកហិរញ្ញវត្ថុអ្នកអាចទាក់ទងទៅសាលាដើម្បីសួរនឹងព័តិមានបន្ថែម។ ពេលខ្លះអ្នកប្រហែលជាត្រូវខ្ចីនូវប្រាក់កំញ្ចីសិស្សមិនថា រដ្ឋ ឬ ក៏ឯកជនអ្នកគួរតែស្រាវជ្រាវអំពីវាផង។ ឧទាហរណ៏ស្រាវជ្រាវអំពីអត្រាការប្រាក់ ឬក៏អ្វីដែលអ្នកអាចប្រើជាមួយនឹងប្រាក់កំញ្ចីនោះ នឹងនៅពេលណាដែលអ្នកគួរតែសងវាវិញផងដែរ- កុំភ្លេចដាក់ពាក្យស្នើរសុំជំនួយផ្នែកហិរិញ្ញវត្ថុ។

FAFSA) - ទីពីរ កុំប្រញ្ញាប់បាក់ទឹកចិត្តពីព្រោះថាស្ទើរតែសាលាទាំងអស់មានសេចក្តីព្រមព្រៀងថា ការដាក់ពាក្យចូលរៀនគឺតម្រូវឱ្យសិស្សរៀនចប់វិទ្យាល័យនឹងទទួលបាននូវពិន្ទុជីភីអេ(GPA) ដ៏សមរម្យមួយ។ ស៊ីនា អ្នកបានខំសិក្សាដើម្បីឱ្យបានឱ្យកាសចូលទៅក្នុងសាកលវិទ្យាល័យ ដូច្នេះកុំឱ្យសាកលវិទ្យាល័យប្រើនូវហេតុផលណាមួយមកបញ្ឈប់អ្នក- និងទីបីកុំភ្លេចអរគុណដល់គ្រូរបស់អ្នកដែលបានសរសេរលិខិតអនុសាសន៏មួយសម្រាប់អ្នកឬនរណាម្នាក់ដែលបានជួយអ្នកជាមួយនឹងដំណើរចូលរៀនមហាវិទ្យាល័យ។ ពួកគេបានលេងជាផ្នែកមួយក្នុងការទទួលយករបស់អ្នកផងដែរហើយពួកគេពិតជានឹងពេញចិត្តក្នុងការស្តាប់វា។

សំណាងល្អ! ល្បែងរង់ចាំគឺគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ!




# The Waiting Game

**by Kayla Chan**

At this point in the school year, seniors should be done applying to colleges. Some seniors may have already heard back from schools if they applied early action. Though the stress of sending applications is over, there is now a new form of stress lingering amongst the students, and it's called the waiting game. Seniors rush home after school, hoping to see a large envelope sticking out from their mailboxes, generally a sure sign of acceptance.




Seniors, hearing back from colleges will bring about a lot of different emotions from disappoint to excitement to jealousy. Please don't get overly disappointed if you didn't get accepted to your top choice or if affording to go to your first choice isn't feasible. Sometimes things work out for the best. I'm a student at UMass Lowell, but it was the last place I wanted to go for school. It wasn't until I attended Accepted Students' Day, where I realized that I could see myself going here. And I'm glad I ended up at this school because I've grown a lot, bothpersonally and academically, and I've had so many wonderful opportunities. In the moment, we never know why life takes us on certain paths, but just believe that it'll take you to where you need to be. And though this advice may not be applicable to you now, you can always transfer schools.

Also at times, you're going to be jealous of your friends and peers who got into a certain school or major, or received more financial aid than you did. But being jealous doesn't change your situation, and being a supportive peer says more about your character than the school you attend.

There are few things you must remember. One, make sure you look at your finances and the amount of aid the schools are giving you and use that as a way to compare your options. If you are unclear about certain terms in scholarships or in the financial aid, call the college to ask. You may have to take out student loans, whether if it's federal or private, so do some research on that too. For instance, look at interest rates, what you can use your loans for, and when you would need to start paying back those loans. Also, don't forget to send and update your Free Application for Federal Student Aid (FAFSA). Second, don't senior slump too much. Almost all schools have a caveat that admission is contingent upon graduating and/or retaining a certain GPA. Seniors, you've worked hard to get into schools, so don't give colleges a reason to rescind your acceptance. And third, don't forget to thank your teachers who wrote a recommendation letter for you or anyone who has helped you with the college process. They played a part in your acceptance too and they'll certainly appreciate it. Good luck! Waiting is just the beginning!



ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# សាលាឧទ្ធរណ៍តម្កល់ការចោទប្រកាន់មនុស្សចំនួន១៣នាក់ ក្នុងសំណុំរឿងនៅផ្លូវវេងស្រេង

**ដោយឃី សុវុឌ្ឍី** | **February 5, 2016**

កាលពីម្សិលមិញសាលាឧទ្ធរណ៍បានតម្កល់ទុកជាបានការនូវការចោទប្រកាន់ពីបទអំពើហិង្សាដោយចេតនា និងបង្កការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិលើមន្ត្រីសហជីព និងកម្មករចំនួន១៣នាក់ ដែលត្រូវបានចាប់ខ្លួនអំឡុងកុបកម្មនៅខាងក្រៅសួនឧស្សាហកម្មមួយក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ ដែលពេលនោះកងរាជអាវុធហត្ថបានបាញ់ស្លាប់មនុស្សយ៉ាងហោចណាស់ប្រាំនាក់។

មនុស្សទាំង១៣នាក់នេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់កាលពីខែមីនា បន្ទាប់ពីសវនាការមួយដែលបណ្តាអង្គការសិទ្ធិមនុស្សយល់ថាមានគុណវិបត្តិ ប៉ុន្តែត្រូវបានដោះលែងឱ្យមានសេរីភាពភ្លាម១ហើយព្យួរទោសជាប់ពន្ធនាគាររបស់ពួកគេ។ សវនាការឧទ្ធរណ៍របស់ពួកគេត្រូវបានធ្វើឡើងកាលពីសប្តាហ៍មុនដោយគ្មានវត្តមានរបស់ពួកគេ។

នៅឯសាលាឧទ្ធរណ៍កាលពីម្សិលមិញ ដែលគ្មានវត្តមានរបស់ជនជាប់ចោទដែរនោះ ចៅក្រមចាយ ច័ន្ទតារាវណ្ណ បានប្រកាសថា សេចក្តីសម្រេចរបស់សាលាដំបូងត្រូវបានតម្កល់ទុកជាបានការ។

ចៅក្រមរូបនេះបានមានប្រសាសន៍ថា "នៅពេលនោះ ឱ្យពេលកុបកម្ម នគរបាលបានប្រាប់ពួកគេឱ្យឈប់ ហើយចាកចេញប៉ុន្តែបាតុករមិនស្តាប់ ហើយពួកគេបានគប់ដុំថ្ម និងដបសាំង និងប្រើប្រាស់ចំពាមកៅស៊ូទៅលើកងរាជអាវុធហត្ថ និងនគរបាលបណ្តាលឱ្យកងរាជអាវុធហត្ថ និងនគរបាលរងរបួសធ្ងន់និងធ្វើឱ្យមន្ត្រីម្នាក់ពិការភ្នែកម្ខាង។ នេះគឺជាទង្វើខុសច្បាប់ដែលបានបង្កការខូចខាតដល់ទ្រព្យសម្បត្តិសាធារណៈ ហើយធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់សក្ខីកម្មរបស់ជនរងគ្រោះ...។ ចៅក្រមសវនាការមិនអាចជឿលើចម្លើយរបស់ចុងចោទដែលនិយាយថា ពួកគេមិនបានចូលរួមបាតុកម្មប៉ុន្តែគ្រាន់តែឈរមើលបានទេ"។

ចៅក្រមរូបនេះមិនបានបកស្រាយថា តុលាការមានភ័ស្តុតាងអ្វីដើម្បីភ្ជាប់ជនជាប់ចោទទៅនឹងអំពើហិង្សានោះឡើយ។ អំឡុងសវនាការដំបូងរបស់ខ្លួននៅសាលាដំបូងរាជធានី ជនជាប់ចោទទាំងអស់សុទ្ធតែអះអាងថាខ្លួនមិនបានចូលរួមក្នុងកុបកម្មហើយត្រូវបានចាប់ខ្លួនដោយគ្រាន់តែពួកគេនៅក្បែរ១នោះ។ នៅពេលមេធាវីរបស់ពួកគេសាកសួរមន្ត្រីថា តើពួកគេបានឃើញចុងចោទណាម្នាក់ក្នុងចំណោមចុងចោទទាំងនេះចូលរួមក្នុងអំពើហិង្សាមែនដែរទេមន្ត្រីទាំងនោះនិយាយថា មិនឃើញទេ។

លោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេតនៅអង្គការសិទ្ធិមនុស្សលីកាដូបានមានប្រសាសន៍កាលពីម្សិលមិញថា មន្ត្រីប្រដាប់អាវុធទាំងនេះបានសារភាពទទួលស្គាល់ដូចគ្នាអំឡុងសវនាការរបស់សាលាឧទ្ធរណ៍កាលពីថ្ងៃទី២៧ ខែមករា។ លោក អំ សំអាត ដែលបានចូលរួមសវនាការនេះបានអះអាងដែរថា ក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលបានឆ្លើយតបនឹងកុបកម្មនោះ គ្មាននរណាម្នាក់ប្រដាប់ដោយអាវុធក្រៅតែពីខែលដំបងនិងទម្របាញ់ឧស្ម័នបង្ហូរទឹកភ្នែកឡើយ។

យ៉ាងហោចណាស់កម្មករកាត់ដេរប្រាំនាក់ត្រូវបានបាញ់ស្លាប់ក្នុងថ្ងៃកុបកម្មនោះ ហើយជាង ៤០នាក់ផ្សេងទៀតរងរបួសដោយសារគ្រាប់កាំភ្លើង។?រូបភាពនៅកន្លែងកើតហេតុបង្ហាញពីសកម្មភាពកងរាជអាវុធហត្ថបាញ់កាំភ្លើងអាកា ៤៧។ គ្មានភ័ស្តុតាងដែលបង្ហាញថា នរណាម្នាក់ផ្សេងទៀតប្រដាប់ដោយអាវុធ ត្រូវបានចុះផ្សាយជាសាធារណៈឡើយ។

លោក អំ សំអាត បានរិះគន់សាលាឧទ្ធរណ៍ចំពោះការបើកសវនាការដោយគ្មានវត្តមានរបស់ចុងចោទ។ លោកបានមានប្រសាសន៍ថា "មេធាវីទាំងអស់របស់ពួកគេបានស្នើសុំឱ្យចៅក្រមសវនាការពន្យារពេលព្រោះពួកគាត់ចង់ស្វែងរកកូនក្តីរបស់ខ្លួនដើម្បីចូលរួមសវនាការ ប៉ុន្តែចៅក្រមមិនយល់ព្រម។ ចៅក្រមការបានបញ្ជូនដីកាទៅកាន់អាសយដ្ឋានរបស់ពួកគេប៉ុណ្ណោះ ប៉ុន្តែពួកគេបានរើចេញអស់ទៅហើយ"។

ពេលទាក់ទងបន្ទាប់ពីសាលដីកានេះត្រូវបានប្រកាសចៅក្រម ចាយ ច័ន្ទតារាវណ្ណ បានបដិសេធមិនធ្វើអត្ថាធិប្បាយទេនៅពេលគេសួរថា ហេតុអ្វីបានជាតុលាការមិនចាត់វិធានការបន្ថែមដើម្បីជូនដំណឹងដល់ចុងចោទអំពីសវនាការនេះដោយបង្វែរសំណួរទៅលោកទូចផារិទ្ធ អ្នកនាំពាក្យតុលាការដែលបដិសេធមិនឆ្លើយបំភ្លឺដូចគ្នា។

ជនជាប់ចោទម្នាក់ឈ្មោះ រស់ សោភ័ណ្ឌ បានអះអាងថា ខ្លួនគឺជាអ្នកឈរមើលដែលគ្មានកំហុសនៅក្នុងថ្ងៃកើតមានកុបកម្ម ហើយនិយាយថា គាត់នឹងនិយាយជាមួយមេធាវីរបស់ខ្លួនថាតើត្រូវប្តឹងសាទុក្ខទៅតុលាការកំពូលឬយ៉ាងណា។គាត់និយាយថា "ខ្ញុំនឹងបន្តស្វែងរកយុត្តិធម៌ ពីព្រោះរឿងនេះអយុត្តិធម៌ណាស់សម្រាប់ខ្ញុំ"៕ **សុខុម**

# APPEAL COURT UPHOLDS VENG SRENG RIOT CONVICTIONS

**byKhySovuthy | February 5, 2016**

The Appeal Court on Thursday upheld convictions of intentional violence and causing property damage against 13 unionists and workers who were arrested during a riot outside a Phnom Penh industrial park on January 3, 2014, at which military police shot dead at least five people.

The 13 were convicted by the Phnom Penh Municipal Court in March, after what rights groups called a flawed trial, but were immediately set free on suspended jail sentences.

Their appeal hearing was held last week in their absence.

At the courthouse on Thursday- and



in the absence of the defendants -Judge ChayChandaravan announced that the lower court's decision had been upheld.

"At the time [of the riot], police told them to stop and leave, but the demonstrators did not listen and they threw stones and bottles of gasoline and used slingshots against the military police and police, which seriously injured the military police and police, and made one officer blind in one eye," the judge said.

"This is an illegal act that caused damage to public property and affected public order," he added. "There is enough evidence to confirm the victims' testimony…. The hearing judges cannot believe the answers of the defendants, who said they did not join the demonstration but were only bystanders who were watching."

The judge did not explain what evidence the court had linking the defendants to the violence.

During their initial trial at the municipal court, the defendants all claimed that they were not participating in the riot and were arrested only because they were in the vicinity. When their lawyers asked the officers if they had seen any of the defendants actually taking part in the violence, the officers said they had not.

Am Sam Ath, technical supervisor for rights group Licadho, said on Thursday that the officers made the same admission during the Appeal Court hearing on January 27.

Mr. Sam Ath, who attended the hearing, said the officers also claimed that none of the police or military police who responded to the riot were armed with anything except shields, batons and tear-gas launchers.

At least five garment workers were fatally shot the day of the riot and more than 40 others were injured by bullets. Photographs of the scene show military police firing AK-47s. No evidence to suggest that anyone else was armed has been made public.

Mr. Sam Ath faulted the appeal court for holding the hearing without any of the defendants.

"All their lawyers asked the hearing judges for a delay because they wanted to find their clients to join the hearing, but the judges did not agree," he said.

"The presiding judge did not give a clear reason for why he did not agree to the delay. He just said that court officials sent a summons to their addresses but they had already moved."

Contacted after the verdict was announced, Judge Chandaravan declined to comment when asked why the court did not take additional steps to inform the defendants of the hearing, referring the question to court spokesman TochPharith, who also declined to comment.

RosSorphon, one of the defendants, maintained that he was an innocent bystander on the day of the riot and said he would talk with his lawyers about whether to appeal the case to the Supreme Court.

"I will continue to search for justice because this is very unfair for me," he said.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ទីបញ្ជាការដ្ឋានអង្គរក្សដែលរើចេញបង្ហាញនូវសញ្ញាទីបញ្ចប់នៃសករាជមួយ

**ដោយឃី សុវុឌ្ឍីនិង Anthony Jensen | February 10, 2016**

អតីតទីបញ្ជាការដ្ឋានអង្គរក្សនៃកងអង្គរក្សផ្ទាល់របស់អតីតប្រធានគណបក្សប្រជាជនកម្ពុជាលោក ជា ស៊ីម ដែលបានរំសាយចោលបន្ទាប់ពីមរណភាពរបស់លោកកាលពីខែមិថុនា គឺឥឡូវនេះជាការិយាល័យរបស់ក្រុមហ៊ុនសន្តិសុខឯកជនមួយ។

សញ្ញាពណ៌ខៀវក្រហមដ៏ធំដែលសរសេរថា "កងអង្គរក្សសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម" នៅខាងលើទ្វារចូលបរិវេណនៅតាមផ្លូវលេខ១៩ក្នុងក្រុងភ្នំពេញត្រូវបានដាក់ជំនួសដោយស្លាកសញ្ញាពីរអមសងខាងទ្វារដែក ពោលគឺរូបសន្តិសុខស្ត្រីនៅម្ខាង និងរូបសន្តិសុខបុរសនៅម្ខាងទៀត ដែលផ្សាយអំពីសេវាក្រុមហ៊ុនសន្តិសុខលីប្រា។

លោក ម៉ម ប៊ុននាង អ្នកនាំពាក្យព្រឹទ្ធសភាបានមានប្រសាសន៍កាលពីថ្ងៃអង្គារថាលោក ជា ស៊ីម ទទួលបានការការពារពីអង្គរក្សរាប់រយនាក់ តែអ្នកទទួលតំណែងស្នងរបស់លោកជាប្រធានព្រឹទ្ធសភាគឺលោក សាយ ឈុំ មានមធ្យោបាយធូររលុងចំពោះសន្តិសុខ។

អ្នកនាំពាក្យព្រឹទ្ធសភារូបនេះបានមានប្រសាសន៍ថា "សម្តេច សាយ ឈុំ មិនមានអង្គរក្សច្រើនដូចសម្តេច ជា ស៊ីម ទេ។ ខ្ញុំឃើញថា គាត់មានអង្គរក្សប្រាំ ឬប្រាំមួយនាក់ប៉ុណ្ណោះដែលទៅតាមសម្តេចពេលលោកទៅណាម្តងៗ"។

លោក ម៉ម ប៊ុននាង បានមានប្រសាសន៍ថា សមាជិកកងអង្គរក្សលោក ជា ស៊ីម ត្រូវបានបញ្ជូនទៅកងពលតូចលេខ៧០ ជាកងយោធពលខេមរភូមិន្ទទទួលបន្ទុកផ្តល់សន្តិសុខដល់មន្ត្រីជាន់ខ្ពស់ និងមន្ត្រីអ្នកមុខអ្នកការបរទេស។

អ្នកវិភាគនយោបាយបាននិយាយថា មានហេតុផលផ្សេងៗដែលក្រុមសន្តិសុខលោក ឈុំ តិចបើប្រៀបធៀបនឹងលោក ជា ស៊ីម ប៉ុន្តែបានយល់ស្របថា កងកម្លាំងធំធេងរបស់លោក ជា ស៊ីម មានប្រយោជន៍តិចតួចសម្រាប់ការពារផ្ទាល់ខ្លួនរបស់លោក។

លោក កែម ឡី អ្នកធ្វើអត្ថាធិប្បាយនយោបាយដែលកាលពីឆ្នាំមុនបានបង្កើតក្រុមតស៊ូមតិមូលដ្ឋានខ្មែរដើម្បីខ្មែរបានមានប្រសាសន៍ថា កងអង្គរក្សលោក ជា ស៊ីម គឺច្រើនតែជាមរតកនៃបក្សនិយមនៅក្នុងជួរគណបក្សកាន់អំណាចនាចុងទសវត្សរ៍ឆ្នាំ១៩៨០ និងទសវត្សរ៍ឆ្នាំ១៩៩០ប៉ុណ្ណោះ។

លោក ឡី បានមានប្រសាសន៍ថា "នេះគឺជាជម្លោះ ហើយប្រធាន និងអនុប្រធានឱ្យនៃគណបក្សប្រជាជនកម្ពុជាខុបានព្យាយាមរើសអង្គរក្សដ៏ច្រើនរហូតមកដល់បច្ចុប្បន្ននេះ។ សាយ ឈុំ នៅពេលនោះគឺស្ថិតនៅកណ្តាល។ អ៊ីចឹងនោះជាហេតុដែល សាយ ឈុំ នឹងមិនរើសអង្គរក្សច្រើនទេ"។

លោក ឡី បាននិយាយបន្ថែមថា ចំពោះមរណភាពនៃលោក ជា ស៊ីម អង្គរក្សរបស់លោកត្រូវផ្លាស់ទៅបម្រើការនៅកន្លែងផ្សេងៗគ្នា។

លោក ឡី បាននិយាយថា "អង្គរក្សគឺមិនត្រឹមតែរក្សាសន្តិសុខឱ្យចៅហ្វាយនាយគេទេ ប៉ុន្តែក៏ការពារមុខជំនួញគេដែរ"។

ទោះបីមានតួនាទីកិត្តិយសនៅក្នុងជួរគណបក្សប្រជាជនកម្ពុជាក្រោយមកនៅក្នុងឆាកជីវិតរបស់លោកក៏ដោយ ក៏លោក ជា ស៊ីម បានបង្កើតនូវបណ្តាញសែស្រឡាយនយោបាយទូលំទូលាយនាទសវត្សរ៍ឆ្នាំ១៩៨០ដែលរយៈពេលជាង១០ឆ្នាំបានធ្វើឱ្យលោកក្លាយជាបុរសមានអំណាចបំផុតម្នាក់ក្នុងបណ្តាអ្នកមានអំណាចជាច្រើនរបស់ប្រទេសកម្ពុជា។

ក្នុងសេចក្តីថ្លែងការណ៍មួយចេញក្រោយពីមរណភាពរបស់លោកកាលពីឆ្នាំមុនអង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch បាននិយាយថា អតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរូបនេះនឹងត្រូវគេចងចាំថាបានបង្កើតឱ្យមានគំរូក្នុងការប្រើខុសនូវកងកម្លាំងសន្តិសុខរដ្ឋ។

លោក ប្រេដ អាដាម នាយកប្រចាំអាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សបាននិយាយក្នុងសេចក្តីថ្លែងការណ៍ថា "មរតករបស់លោកបន្តរហូតមកដល់សព្វថ្ងៃនេះ ដោយមានកងកម្លាំងសន្តិសុខមិនមានការកែទម្រង់ គឺធ្វើឡើងសម្រាប់តែផលប្រយោជន៍គណបក្សកាន់អំណាចជាជាងសម្រាប់សាធារណជន"។

កងអង្គរក្សដ៏ធំធេងរបស់លោក ជា ស៊ីម និងបញ្ជីទីប្រឹក្សាច្រើននាក់របស់លោកមានឈ្មោះក្នុងបញ្ហាផ្លូវច្បាប់ ដោយមានអតីតប្រធានកងអង្គរក្សរបស់លោកត្រូវបានតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល១០ឆ្នាំពីបទប្រព្រឹត្តល្មើស ជាច្រើន។

តទៅទំព័រទី១៦

# VACATED BODYGUARD HQ SIGNALS END OF AN ERA

**byKhySovuthy and Anthony Jensen | February 10, 2016**

The former headquarters of late CPP President Chea Sim's personal bodyguard unit, which was disbanded following his death in June, is now the office of a private security firm.

The large blue-and-red sign reading "Bodyguard Unit of Sam-dech Akka MohaThammaPothisal Chea Sim" above the entrance to the compound on Street 19 in Phnom Penh has been replaced by two posters flanking a metal gate-the image of a female security guard on one side, a male counterpart on the other-advertising the services of Libra Private Security.

While Chea Sim enjoyed the protection of hundreds of armed bodyguards, his successor as president of the Senate, Say Chhum, has taken a more relaxed approach to security, Senate spokesman Mam Bun Neang said on Tuesday.

"Samdech Say Chhum does not have many bodyguards like Samdech Chea Sim," he said. "I have seen that he has about five to six bodyguards, who go with Samdech whenever he goes anywhere."

Mr. Bun Neang said members of Chea Sim's bodyguard unit had been reassigned to Brigade 70-the Royal Cambodian Armed Forces unit tasked with providing security to high-level officials and foreign dignitaries.

Political analysts said there could be various reasons why Mr. Chhum's security detail paled in comparison to his predecessor's but agreed that Chea Sim's massive force had little to do with his personal protection.

Political commentator Kem Ley, who last year founded the Khmer for Khmer grassroots advocacy group, said Chea Sim's bodyguard unit was largely a legacy of the factionalism within the ruling party in the late 1980s and 1990s.

"This was the conflict, and the chairs and vice-chairs [of the CPP] tried to recruit many, many bodyguards until now," Mr. Ley said.

"Say Chhum at that time was in the middle. So that's why I hope Say Chhum will not recruit many bodyguards," he said, adding that toward the end of Chea Sim's life, his bodyguards served in various functions.

"The bodyguard is not only to maintain the security of their boss, but their business also," he said.

Although he served a mostly honorary role within the CPP later in his life, Chea Sim created a sprawling political patronage network in the 1980s that for more than a decade made him one of the country's most powerful men.

In a statement released following his death last year, Human Rights Watch said the former interior minister would be remembered for creating a template for the misuse of state security forces.

"His legacy continues to this day, with unreformed security forces run for the interests of the ruling party instead of the public good," the group's Asia director, Brad Adams, said in the statement.

Chea Sim's massive bodyguard unit and his long list of advisers were notorious for finding themselves in legal trouble, with his former bodyguard chief handed a 10-year prison sentence for a long list of crimes.

ChhoeunChanthan, the disgraced bodyguard chief, was convicted in February 2012 of illegal weapons possession, ordering the use of weapons without proper authority, forging documents and using forged documents. In the same month, a military court convicted him of illegally selling and destroying military property, as well as breach of trust.

Ou Virak, a political analyst and head of the Future Forum think tank, said bodyguards in Cambodia were largely a "power symbol," and one that he was happy to see diminished in the case of Chea Sim.

"I think it was basically Chea Sim's way of saying he was still important in the party. Say Chhum cannot demand the same thing, nor should he," he said.

"Many of the Cambodian people who have bodyguards do not have them for protection of the body," Mr. Virak said, pointing to Mr. Hun Sen's bodyguard unit, which numbers in the thousands.

"Does Hun Sen really need the bodyguard unit? You could have asked the same thing about Chea Sim," he added. "The answer is no."

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី

# លោក ហ៊ុន សែន ច្រានចោលការរិះគន់របស់បរទេសនៅមុនកិច្ចប្រជុំកំពូល

**ដោយ គុច ណារ៉េន** | **February 16, 2016**

ដោយចាប់ផ្ដើមដំណើរបំពេញទស្សនកិច្ចជាផ្លូវការលើកដំបូងរបស់ខ្លួនទៅកាន់សហរដ្ឋអាមេរិកសម្រាប់កិច្ចប្រជុំកំពូលជាមួយលោក បារ៉ាក់ អូបាម៉ា ប្រធានាធិបតីអាមេរិក និងមេដឹកនាំអាស៊ានផ្សេងៗទៀតនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងកាលពីល្ងាចថ្ងៃអាទិត្យថា លោកមិនចាប់អារម្មណ៍នឹងការរិះគន់ពីសំណាក់សហរដ្ឋអាមេរិកដែលជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលនេះឡើយ ។

ពេលថ្លែងទៅកាន់អ្នកគាំទ្ររាប់រយនាក់នៅឯសណ្ឋាគារមួយក្បែរកន្លែងរៀបចំកិច្ចប្រជុំកំពូលនេះនៅក្នុងទីក្រុង Rancho Mirage រដ្ឋកាលីហ្វ័រញ៉ាលោក ហ៊ុន សែន បានលើកឡើងថា លោកមិនរវីរវល់អានលិខិតក្នុងពេលថ្មីៗពីសមាជិកសភាអាមេរិកដែលលើកឡើងអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាឡើយ ។

លោក ហ៊ុន សែន បានថ្លែងទៅកាន់អ្នកចូលរួម ដែលក្នុងនោះមានរួមទាំងសមាជិកដ៏លេចធ្លោមួយចំនួននៃសហគមន៍ខ្មែរអាមេរិកាំងនៅក្នុងវីដេអូមួយបង្ហោះតាមហ្វេសប៊ុកថា "អ្នកឯងមានសិទ្ធិផ្ញើសំបុត្រឱ្យខ្ញុំ ខ្ញុំមានសិទ្ធិអត់ទទួល" ។

នៅក្នុងលិខិតមួយច្បាប់ផ្ញើជូនលោក ហ៊ុន សែន ចុះថ្ងៃទី១១ ខែកុម្ភៈ សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិកមកពីគណបក្សប្រជាធិបតេយ្យចំនួន៧រូប បានសំដែងក្ដីព្រួយបារម្ភរបស់ខ្លួនជុំវិញប្រវត្តិសិទ្ធិមនុស្សក្រោមការដឹកនាំរបស់រដ្ឋាភិបាលលោក ហ៊ុន សែន ដោយលើកឡើងអំពីការវាយដំយ៉ាងព្រៃផ្សៃលើតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំនួនពីររូបនៅខាងក្រៅរដ្ឋសភាកាលពីខែតុលាដោយអមជាមួយនឹងរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលស្ដីអំពីការរំលោភយកដី និងការជួញដូរមនុស្ស ។

លោក ហ៊ុន សែន បានមានប្រសាសន៍ថា "ខ្ញុំថា ខ្ចប់ស្រោមសំបុត្របញ្ជូនទៅឱ្យម្ចាស់ដើមវិញទៅ" ។

លោកបានបន្ថែមពេលមានការអបអរសាទរពីអ្នកចូលរួមថា "សូម្បីតែសំបុត្រអូបាម៉ា ក៏ដោយបើថា សំបុត្រហ្នឹង ឃើញគេមកជេរខ្ញុំ ខ្ញុំចាំតែទទួលតើ" ។

ដំណើរបំពេញទស្សនកិច្ចរបស់លោក ហ៊ុន សែន ទៅកាន់សហរដ្ឋអាមេរិកស្ថិតក្នុងស្ថានភាពដ៏ចម្រូងចម្រាស ។

អង្គការសិទ្ធិមនុស្សរាប់សិបបានអំពាវនាវ



លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងអំឡុងពេលជួបជាមួយអ្នកគាំទ្រនៅសណ្ឋាគារមួយនាភាគខាងត្បូងរដ្ឋកាលីហ្វ័រញ៉ា កាលពីល្ងាចថ្ងៃអាទិត្យ ។ លោកបានច្រានចោលការរិះគន់របស់បរទេសនៅមុនកិច្ចប្រជុំកំពូលដែលធ្វើឡើងក្នុងរដ្ឋនេះ ។ រូបថត: AKP-TVK

ឱ្យលោក បារ៉ាក់ អូបាម៉ា ដោះស្រាយការរំលោភបំពានសិទ្ធិមនុស្សនៅក្នុងតំបន់ ទោះបីជាកិច្ចប្រជុំកំពូលនេះទំនងជាផ្ដោតលើពាណិជ្ជកម្ម និងសន្តិសុខក៏ដោយ ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សបានលើកឡើងក្នុងសេចក្ដីថ្លែងការណ៍មួយចេញកាលពីដើមសប្ដាហ៍នេះថា "លោក បារ៉ាក់ អូបាម៉ា ក៏គួរតែដាក់សម្ពាធជាសាធារណៈលើលោក ហ៊ុន សែន ឱ្យបញ្ចប់អំពើហិង្សា និងការយាយីរំខានអ្នក គាំទ្រគណបក្សប្រឆាំងលើកលែងការចោទប្រកាន់អ្នកតវ៉ាដោយសន្តិវិធីពីបទព្រហ្មទណ្ឌ និងដោះលែងអ្នកទោសនយោបាយទាំងអស់ទូទាំងប្រទេសផងដែរ" ។

ក្រុមអាណិកជនខ្មែររស់នៅសហរដ្ឋអាមេរិកក៏បានសន្យាថា នឹងធ្វើការតវ៉ាជាសាធារណៈប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រីអំឡុងកិច្ចប្រជុំកំពូលរយៈពេលពីរថ្ងៃនៅរមណីយដ្ឋាន Sunny lands ផងដែរ ។ លោកទូច វិបុល ប្រធានសម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំងជាក្រុមសកម្មជនដែលកំពុងរៀបចំបាតុកម្មនោះបានលើកឡើងតាមសារអេឡិចត្រូនិកកាលពីម្សិលមិញថា លោករំពឹងថា នឹងមានអ្នកតវ៉ា៥០០នាក់ចេញមកតវ៉ា ។

លោក ហ៊ុន សែន បានព្រមានថា បើ

**តទៅទំព័រទី ២០**

# HUN SEN DISMISSES US CRITICS AHEAD OF SUMMIT

**byKuchNaren | February 16, 2016**

Beginning his first official visit to the U.S. for a summit with fellow Asean leaders and U.S. President Barack Obama in California this week, Prime Minister Hun Sen said on Sunday evening that he was not interested in critiques leveled by his American hosts.

Speaking to hundreds of supporters at a hotel near the site of the summit in Rancho Mirage, California, Mr. Hun Sen said he had not even bothered to read a recent letter from U.S. lawmakers commenting on Cambodia's human rights situation.

"You have the right to send me a letter; I have the right not to receive it," Mr. Hun Sen told the audience-including a number of prominent members of the Cambodian-American community-in a video posted to Facebook.

In a letter to Mr. Hun Sen dated February 11, a group of seven Democratic U.S. senators expressed their concern over the human rights record of his government, citing the brutal beating of two CNRP lawmakers outside the National Assembly in October, along with NGO reports on land grabbing and human trafficking.

"I ordered that the letter be put back in the envelope and sent back to the original senders," Mr. Hun Sen said.

"Even if it's a letter from Obama, I would never receive it if the letter was just insulting me," he added, to applause from his audience.

Mr. Hun Sen's trip to the U.S. has been mired in controversy.

Dozens of human rights groups have called on Mr. Obama to address human rights abuses in the region, despite the summit ostensibly focusing on trade and security.

"Obama should also publicly press Hun Sen to end violence and harassment of opposition supporters, drop criminal charges against peaceful protesters, and release all political prisoners in the country," Human Rights Watch said in a statement released earlier this month.

Activists in the U.S. have also promised public protests against the prime minister during the two-day summit at the Sunnylands resort. Vibol Touch, president of the Cambodia-America Alliance, an activist group that is organizing the demonstration, said in an online message on Monday that he expected a turnout of 500 protesters.

Mr. Hun Sen has warned that any protests held against him could lead to counterdemonstrations back in Cambodia, and ruling party supporters have alluded to possible violent retribution against CNRP officials.

The opposition party has repeatedly said it is not involved with the Cambodian-American activists.

In a post to his Facebook page on Monday, hours before the Cambodia-America Alliance's protest was set to begin, Mr. Hun Sen said demonstrations would only play into the hands of his foreign critics.

"Please do not have internal disputes and then take those disputes abroad, tearing each other apart and destroying Cambodians' happiness, making foreigners trample and look down on our race," he wrote.

Mr. Hun Sen has previously shown his sensitivity to protests staged against him in foreign countries. After he was met by protesters during a trip to France in October, he warned of counterprotests in Cambodia. The next day, two opposition lawmakers were beaten and left with severe injuries at an anti-CNRP protest outside Parliament.

In the past week, the CNRP has sent letters to both **Contiued to Page 23**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ដោយមានស្លាកសញ្ញាថ្មី លោក ញឹក ប៊ុនឆៃ ជំរុញបក្សទៅមុខ

**ដោយឃួន ណារិម** | **February 13, 2016**

លោក ញឹក ប៊ុនឆៃ អតីតឧត្តមសេនីយ៍ គណបក្សហ៊្វុនស៊ិនប៉ិចបានប្រកាសក្នុងសន្និសីទកាសែតមួយនៅឯផ្ទះរបស់លោកកាលពីថ្ងៃសុក្រថា គណបក្សរាជានិយមថ្មីមួយដែលលោកបានបង្កើតឡើងត្រូវបានយល់ព្រមដោយក្រសួងមហាផ្ទៃ ហើយនឹងធ្វើសមាជរបស់ខ្លួននៅចុងខែនេះ។

លោកបានមានប្រសាសន៍ថា "ខ្ញុំឃើញថា ឱ្យទ្រង់រណឫទ្ធិ បោះបង់ចោលស្លាកសញ្ញាចាស់នៃវិមានឯករាជ្យដែលជាកេរដំណែលសម្តេចតាអ៊ីចឹងយើងបានសម្រេចយកមកប្រើវិញសម្រាប់គណបក្សខ្មែររួបរួមជាតិ ព្រោះយើងចង់រក្សានូវអ្វីដែលយើងគិតថាគេបំភ្លេចចោល"។

ទោះបីភ្ជាប់ទៅនឹងស្លាកសញ្ញាចាស់ក៏ដោយក៏លោក ប៊ុនឆៃ បាននិយាយថា លោកមានរូប



គណបក្សហ៊្វុនស៊ិនប៉ិចដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ

ទោះបីជាសន្និសីទនេះបានធ្វើឡើងដើម្បីជូនដំណឹងដល់សាធារណជនស្តីពីគណបក្សនយោបាយថ្មីដែលលោកដាក់ឈ្មោះថា គណបក្សខ្មែររួបរួមជាតិក៏ដោយ ក៏លោក ប៊ុនឆៃ ប្រើពេលភាគច្រើនរបស់លោករិះគន់គណបក្សហ៊្វុនស៊ិនប៉ិច និងប្រធានបក្សគឺព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ជាអតីតប្រធានរបស់លោក និងជាសត្រូវនាពេលបច្ចុប្បន្ន។

លោក ប៊ុនឆៃ ត្រូវបានបង្ខំនៅសប្តាហ៍នេះ ឱ្យផ្លាស់ប្តូរស្លាកសញ្ញាដែលលោកបានដាក់ប្រើសម្រាប់បក្សថ្មីរបស់លោក គឺស្រដៀងគ្នានឹងស្លាកសញ្ញាដែលធ្លាប់ប្រើដោយគណបក្សហ៊្វុនស៊ិនប៉ិច បន្ទាប់ពីព្រះអង្គម្ចាស់ រណឫទ្ធិ តវ៉ាទៅក្រសួងមហាផ្ទៃ។

កាលពីថ្ងៃសុក្រលោកបានទទួលស្គាល់ថា លោកនឹងផ្លាស់ប្តូរស្លាកសញ្ញា ប៉ុន្តែបានមានប្រសាសន៍ថា ជាការអាម៉ាស់ដែលព្រះអង្គម្ចាស់មិនប្រើស្លាកសញ្ញានោះ។

សញ្ញាថ្មីគឺ មកុដមួយ និងកួរស្រូវពីរកួររំលេចដោយពណ៌លឿង និងខៀវ។

លោក ប៊ុនឆៃ ក៏បានផ្តល់យោបល់ថា បក្សរបស់លោកនឹងព្យាយាមយកមកវិញនូវស្នាក់ការតាមខេត្តមួយចំនួនរបស់គណបក្សហ៊្វុនស៊ិនប៉ិច ដោយអះអាងថា មានស្នាក់ការប្រហែល១០កន្លែងជាកម្មសិទ្ធិឯកជនមានដូចជារូបលោក និង លោក កែវ ពុទ្ធរស្មី អតីតប្រធានគណបក្សហ៊្វុនស៊ិនប៉ិច។

លោកបានមានប្រសាសន៍ថា "មិនមែនស្នាក់ការទាំងអស់បង្កើតឡើង និងដឹកនាំដោយសម្តេចក្រុមព្រះ ឱ្យរណឫទ្ធិ" ទេ។ ប្រសិនបើសម្តេចក្រុមព្រះ និងអ្នកផ្សេងទៀតជុំវិញព្រះអង្គចង់យកស្នាក់ការនឹងមានការប្តឹងផ្តល់គ្នាហើយ"។

មន្ត្រីគណបក្សហ៊្វុនស៊ិនប៉ិចមិនអាចទាក់ទងសុំការធ្វើអត្ថាធិប្បាយបានទេ៕ **វីន**

# WITH NEW LOGO, NHEK BUN CHHAY PRESSES AHEAD WITH PARTY PLANS

**byKhuonNarim | February 13, 2016**

A new royalist political party founded by former Funcinpec general Nhek Bun Chhay has been approved by the Interior Ministry and will hold its inaugural congress later this month, he said at a press conference at his house on Friday.

Although the event was ostensibly



គណបក្សខ្មែររួបរួមជាតិដឹកនាំដោយឧត្តមសេនីយ៍ ញឹក ប៊ុនឆៃ

held to inform the public about his new political venture, which he has dubbed the Khmer National United Party, Mr. Bun Chhay spent much of his time criticizing Funcinpec and its leader, Prince Norodom Ranariddh, his former boss and current nemesis.

Mr. Bun Chhay was forced this week to change the logo he proposed to use for his new party, which was nearly identical to a logo formerly used by Funcinpec, after Prince Ranariddh complained to the Interior Ministry.

On Friday, he conceded that he would change the logo, but said it was a shame that the prince had let the image fall out of use.

"I saw that [Prince Ranariddh] had abandoned the old logo of Independence Monument that was the heritage of the late king, so we all decided to retake it to use for the new Khmer National United Party because we want to maintain what we think they have forgotten," he said.

Despite his attachment to the old logo, Mr. Bun Chhay said he had already come up with a new emblem: a crown and two sheaves of rice, rendered in yellow and blue.

Mr. Bun Chhay also suggested that his party would try to take over some of Funcinpec's provincial offices, claiming that around 10 of them were privately owned by people such as himself and Keo PuthReasmey, the former head of Funcinpec.

"Not all the offices were created and led by SamdechKromPreah [Prince Ranariddh]," he said.

"If SamdechKromPreah and others around him want to take the offices, a lawsuit cannot be avoided."

Funcinpec officials could not be reached for comment.

narim@cambodiadaily.com

តមកពីទំព័រទី ១៩ ទីបញ្ជាដ្ឋានអង្គរក្សដែលរើចេញ...

ឈឿន ចាន់ថន ប្រធានអង្គរក្សធ្លាក់សក្តិត្រូវបានកាត់ឱ្យជាប់ទោសកាលពីខែកុម្ភៈ ឆ្នាំ២០១២ពីបទកាន់កាប់អាវុធខុសច្បាប់ ពីបទបញ្ជាឱ្យប្រើអាវុធដោយគ្មានការអនុញ្ញាតត្រឹមត្រូវក្លែងឯកសារ និងប្រើប្រាស់ឯកសារក្លែងក្លាយ។ នៅក្នុងខែដដែលនោះតុលាការយោធាបានផ្តន្ទាទោសអតីតប្រធានអង្គរក្សរូបនេះពីបទលក់ និងបំផ្លាញទ្រព្យសម្បត្តិយោធាដោយខុសច្បាប់ ក៏ដូចជារំលោភសេចក្តីទុកចិត្ត។

លោក អ៊ូ វីរៈ អ្នកវិភាគនយោបាយ និងជានាយកវេទិកាអនាគតបានមានប្រសាសន៍ថា អង្គរក្សនៅក្នុងប្រទេសកម្ពុជា គឺភាគច្រើនជានិមិត្តរូបអំណាច ហើយជាអង្គរក្សដែលលោកត្រេកអរនឹងឃើញហោចទៅក្នុងករណីលោក ជា ស៊ីម។

អ្នកវិភាគនយោបាយរូបនេះបានមានប្រសាសន៍ថា "ខ្ញុំគិតថា ជាបឋមជាវិធីនិយាយរបស់ ជា ស៊ីម ថា លោកនៅតែជាមនុស្សសំខាន់នៅក្នុងជួរបក្ស។ សាយ ឈុំ មិនអាចទាមទារអ្វីៗដូចគ្នាបានទេ ហើយលោកក៏មិនគួរទាមទារដែរ"។

លោក វីរៈ បានមានប្រសាសន៍សំដៅលើក្រុមអង្គរក្សលោក ហ៊ុន សែន ដែលមានចំនួនរាប់ពាន់នាក់ថា "ពលរដ្ឋខ្មែរជាច្រើនដែលមានអង្គរក្សមិនមែនយកពួកគេមកដើម្បីការពារខ្លួនពួកគេទេ"។

លោក វីរៈ បានមានប្រសាសន៍បន្ថែមថា " តើ ហ៊ុន សែន ពិតជាត្រូវការក្រុមអង្គរក្សមែនទេ? អ្នកអាចសួរចំណុចដូចគ្នានេះអំពី ជា ស៊ីម។ ចម្លើយគឺអត់ទេ"៕

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ការគំរាមធ្វើបាតុកម្មតបតមិនអាចរារាំងបាតុកម្ម ប្រឆាំងលោក ហ៊ុន សែន នៅអាមេរិក

**ដោយ គុច ណារ៉េន និង Anthony Jensen | February 17, 2016**

ដោយអ្នកតវ៉ាដែលជាអាណិកជនខ្មែររស់នៅសហរដ្ឋអាមេរិកនាំគ្នាចេញមកធ្វើបាតុកម្មនៅលើផ្លូវមួយដែលស្ថិតនៅឆ្ងាយពីរមណីយដ្ឋាន Sunnylands នាភាគខាងត្បូងរដ្ឋកាលីហ្វ័រញ៉ានោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្វាគមន៍លោក បារ៉ាក់ អូបាម៉ា ប្រធានាធិបតីសហរដ្ឋអាមេរិក និងបានថតរូបពេលចាប់ដៃគ្នាដោយគ្មានការរំខានកាលពីថ្ងៃច័ន្ទ មុនពេលកិច្ចប្រជុំកំពូលអាមេរិក-អាស៊ានដែលមានរយៈពេលពីរថ្ងៃចាប់ផ្តើម។

បាតុកម្មនេះដែលរៀបចំដោយសម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំង ជាក្រុមសកម្មជនមានមូលដ្ឋាននៅក្នុងរដ្ឋការ៉ូលីណា ខាងជើងបានធ្វើឡើងតាមគ្រោងទុកក្រោយពេលមានការប្រមែប្រមូលគ្នាជាច្រើនសប្តាហ៍-ដែលអំឡុងពេលនោះអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចបានព្រមានពីការឆ្លើយតបដ៏ហិង្សា ប្រសិនបើបាតុកម្មនេះនៅតែធ្វើឡើង។

ទោះបីជាមានការគំរាមយ៉ាងនេះក្តីដែលរួមមានការនិយាយបញ្ឆិតបញ្ឆៀងដល់ការវាយដំយ៉ាងសាហាវលើតំណាងរាស្ត្រគណបក្សប្រឆាំងពីររូបនៅខាងក្រៅរដ្ឋសភាក្នុងរាជធានីភ្នំពេញកាលពីខែតុលាក្តី តែប្រតិកម្មកាលពីម្សិលមិញ ចំពោះបាតុកម្មនេះគ្មានសកម្មភាពអ្វីទេ ដោយសារមានការប្រទាំងប្រទើសជុំវិញទំហំនៃបាតុកម្មនេះ។

លោក រឿន វាសនា អនុប្រធានសម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំងបានលើកឡើងថា បាតុកម្មនៅក្នុងក្រុង Rancho Mirage រដ្ឋកាលីហ្វ័រញ៉ា មានអ្នកចូលរួមជាង១.០០០នាក់ ក្នុងនោះភាគច្រើនមកពីសមាគមខ្មែរនៅសហរដ្ឋអាមេរិក និងកាណាដា។

លោក រឿន វាសនា បានលើកឡើងថា "យើងឃើញថា មានចំនួនសរុបយ៉ាងតិច១.៥០០នាក់"។ លោកបានបន្ថែមថា "ក្នុងនោះ៨០ភាគរយមកពីចលនាប្រជាជនខ្មែរ រីឯអ្នកផ្សេងទៀតគឺជាពលរដ្ឋថៃពលរដ្ឋវៀតណាម ពលរដ្ឋរ៉ូហ៊ីងយ៉ា និងអ្នកតវ៉ាប្រឆាំងកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP)"។

រូបភាពនៃបាតុកម្មនេះបង្ហាញឱ្យឃើញថាអ្នកតវ៉ាឈរនៅពីក្រោយរបាំងដោយមានលើកបដាប្រឆាំងលោក ហ៊ុន សែន និងប្រវត្តិសិទ្ធិមនុស្សរបស់រដ្ឋាភិបាលលោក។ បដាមួយមានអត្ថន័យថា "បញ្ហាអាយុជីវិតប្រជាពលរដ្ឋខ្មែរ" រីឯបដាមួយទៀតមានអត្ថន័យថា "អាមេរិក=លទ្ធិប្រជាធិបតេយ្យ,កម្ពុជា=លទ្ធិប្រជាធិបតេយ្យក្លែងក្លាយ" ហើយបដាមួយផ្សេងទៀតមានអត្ថន័យថា "ហ៊ុន សែន គឺជាឃាតករ"។

លោក រឿន វាសនា បានមានប្រសាសន៍ថា "សារដ៏សំខាន់បំផុតនោះ គឺយើងឆ្អែតឆ្អន់នឹងការគ្មានតម្លាភាពអស់រយៈពេល៣៥ឆ្នាំមកហើយ ឆ្អែតឆ្អន់នឹងរដ្ឋាភិបាលផ្តាច់ការដែលកាន់អំណាចអស់រយៈពេល៣៥ឆ្នាំមកនេះ និងឆ្អែតឆ្អន់ចំពោះអំណាចផ្តាច់ការ"។ លោកបានបន្ថែមថា "យើងចង់ឃើញរដ្ឋាភិបាលដែលមានការទទួលខុសត្រូវ ហើយយើងគិតថា យើងនឹងមិនទទួលបានបែបនេះទេ បើ ហ៊ុន សែន នៅតែកាន់អំណាចនោះ"។

ដោយនិយាយផ្ទុយទាក់ទិនទៅនឹងការប៉ាន់ប្រមាណរបស់លោក រឿន វាសនា ដែលថាបាតុកម្មមានអ្នកចូលរួមយ៉ាងច្រើននោះលោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានលើកឡើងថា ប្រភពផ្ទាល់របស់លោកដែលបដិសេធសុំមិនបញ្ចេញ ឈ្មោះបានប្រាប់លោកថាសកម្មជនរូបនេះនិយាយបំផ្លើសចំនួននៃអ្នកចូលរួមដែលជាអាណិកជនខ្មែររស់នៅសហរដ្ឋអាមេរិកដែលថា មានប្រហែល៩០០នាក់នោះ។

លោក សុខ ឥសាន បានថ្លែងថា "ព័ត៌មានដែលខ្ញុំទទួលបានគឺថា ពួកគេត្រូវការជាង៩៤០នាក់ទៀតទើបដល់ចំនួន១.០០០នាក់"។

ដោយច្រានចោលការលើកឡើងដែលថាចលនាប្រជាជនខ្មែរជាទូទៅមិនពេញចិត្តនឹងលោក ហ៊ុន សែន នោះ លោក បានលើកឡើងថា

**តទៅទំព័រទី ២១**



អ្នកតវ៉ានាំគ្នាធ្វើបាតុកម្មប្រឆាំងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅខាងក្រៅរមណីយដ្ឋាន Sunnylands ក្នុងទីក្រុង Rancho Mirage រដ្ឋកាលីហ្វ័រញ៉ាសហរដ្ឋអាមេរិក កាលពីថ្ងៃច័ន្ទ។

# THREATS FAIL TO THWART ANTI-HUN SEN PROTEST

**byKuchNaren and Anthony Jensen | February 17, 2016**

With Cambodian-American protesters sequestered on a street away from the Sunnylands resort in southern California, Prime Minister Hun Sen greeted U.S. President Barack Obama and posed for a handshake free from harassment on Monday before the start of a two-day U.S.-Asean summit.

The protest, organized by the Cambodia-America Alliance, an activist group based in North Carolina, went ahead following weeks of buildup during which supporters of the ruling CPP warned of a violent response if the demonstration took place.US President Barack Obama greets Prime Minister Hun Sen on the first day of the US-Asean summit in Rancho Mirage, California, on Monday. (Reuters)

Despite the threats, which included allusions to the vicious beating of two opposition lawmakers outside the National Assembly in Phnom Penh in October, Tuesday's reaction to the protest was limited, mostly due to disputes over its size.

Veasna Roeun, vice president of the Cambodia-America Alliance, said that at its peak the protest in Rancho Mirage, California, numbered more than a thousand people, most of them from Cambodian communities in the U.S. and Canada.

"We are looking at a combined total of at least 1,500," Mr. Roeun said, adding that "a good 80 percent" were from the Cambodian diaspora, the remainder being Thai, Vietnamese, Rohingya and anti-Trans-Pacific Partnership demonstrators.

Photographs of the demonstration showed protesters standing behind barricades hoisting signs railing against Mr. Hun Sen and his government's rights record. One read "Cambodian Lives Matter," another "America = Democracy, Cambodia = 'Dumb'mocracy." Yet another read "Hun Sen is a Killer."

Protesters demonstrate against Prime Minister Hun Sen outside the Sunnylands resort in Rancho Mirage, California, on Monday. (Reuters)

"The main message is that we are fed up with the 35 years of no transparency, of 35 years of authoritarian government, of dictatorial rule," Mr. Roeun said. "We want to see responsible government, and we don't think we are going to get that while Hun Sen is sitting in power."

Contradicting Mr. Roeun's estimate of the crowd size, CPP spokesman Sok Eysan said his own sources, which he refused to name, informed him that the activist had oversold the number of Cambodian-Americans in attendance-by about 900 people.

"The information I've received is that they would have needed 940 more people to meet a number of 1,000 demonstrators," Mr. Eysan said.

"This proves that they were met with failure because there were only 50 to 60 people who joined the protest," he said, dismissing the notion that the Cambodian diaspora was generally unhappy with Mr. Hun Sen.

"The most noticeable thing was that anti-Thai government demonstrators greeted and thanked SamdechTecho Hun Sen for supporting the fight for democracy in Thailand," he said.

**Continued to Page 21**

តមកពីទំព័រទី ០១

## ឆ្នាំ២០១៦ ត្រៀមជូនដំណើរជ័យជំនះ...

បន្តិចគេនឹងឃើញថា លោក ហ៊ុន សែន សាងអំណាច សាង សម្បត្តិ សម្រាប់តែក្រុមគ្រួសារខ្លួនឯងតែម្នាក់ប៉ុណ្ណោះ អ្នកឯទៀតគ្រាន់តែជួយលំអដំណើរទៅរកអំណាចដែលគំរូគឺ គីម យ៉ុងអ៊ូន នៃប្រទេសកូរ៉េខាងជើងនោះទេ។

ប្រជាពលរដ្ឋខ្មែរបានសិក្សានិងភ្លក់ក្បួនបីសាចច្រើនឆ្នាំ លែង"ព្រឺរោម"នឹងការគម្រាមទាំងឡាយនោះតទៅទៀតហើយ។ ពួកគេបានសម្រេចចិត្តយ៉ាងមាំថា"ពេលវេលានឹងមកដល់គេនឹងផ្លាស់ប្តូររបបនោះចេញ" អ្នកណាចង់កាត់ដៃខ្លួន ក៏កាត់ទៅពេលវេលាមកដល់ សម រង្ស៊ី នឹងមកដល់ភ្នំពេញតែដដែល ដូចដែលយើងធ្លាប់ឃើញ... សម្ភោធបង្គោលព្រំដែនអីក៏សម្ភោធទៅវៀតណាមនឹងបរិវានឹងទទួលសំណងពីគំនុំដែលខ្លួនចិញ្ចឹមនៅពេលវេលាមួយដែលនឹងមកដល់ដូចគ្នាគេថា "កាលណាគេដាំខ្យល់វាដុះជាព្យុះ"។

តើផលវិបាកអ្វីខ្លះដែលនឹងមកដល់ជា"ខ្យល់ព្យុះ"នោះ រដ្ឋាភិបាលកំពុងដាំៈ

១-អ្នកក្រីក្ររស់លើគំនរសម្រាម-អ្នកគ្មានជម្រក គ្មានដីស្រែចំការ -កម្មកររាប់ម៉ឺនសែនរស់នៅតែក្រីក្រគ្មានកិច្ចការពារ -នេះគឺជាការបណ្តុះ"ព្យុះ"បដិវត្តន៍នៃវណ្ណៈអធន ២-អ្នករាជការក្រីក្ររស់ដោយជំពាក់គុណអ្នកធំ -អ្នករកស៊ីមានបានបន្តិចបន្តួចឬក៏បានគ្រាន់បើដោយសារល្បិចកល -រៀនសូត្របានការងារសមរម្យទាល់តែពូកែប្រណិបត្តិ នេះគឺជាការបណ្តុះ"ព្យុះ"អយុត្តិធមិ ៣-"គុក"កាន់តែរីកធំមិនមែនដោយសារច្បាប់


លោក ហ៊ុន សែន


លោក សម រង្ស៊ី

តែប្រឆាំងនឹងបំណងអ្នកមានអំណាច -ទំហំនៃការគិតបញ្ចេញមតិដោយសេរី សិទ្ធិមានទ្រព្យសម្បត្តិជាឯកជនដោយសេរីបានត្រូវរំលោភដោយកម្លាំងអាជ្ញាធរនៃគណបក្សកាន់អំណាច -ទាំងនេះគឺការបណ្តុះ"ព្យុះ"នៃសេរីភាព -នៅមានទី៤-មួយទៀត ដែលទាក់ទងទៅនឹងការលក់សម្បត្តិជាតិដោយគ្មានរវល់នឹងការគ្រោះថ្នាក់ដល់អាយុជីវិតជាតិនឹងពិភពលោក ខ្លាំងជាងនេះទៅទៀតការគិតដល់ប្រយោជន៍ជនជាតិវៀតណាមដល់យោធាវៀតណាមឱ្យនៅក្នុងទឹកដីកម្ពុជាជាងអាយុជីវិតជនកម្ពុជាខ្លួនឯង គឺជា"ព្យុះ"នៃកម្លាំងស្នេហាជាតិ។

តើនៅមានចន្លោះត្រង់ណាដែលគណបក្សប្រជាជនកាន់អំណាច ធ្វើអ្វីដើម្បីបណ្តុះ"ខ្យល់"សន្តិភាពដែរ ឬទេ?មានដែរ ដែលមនុស្សមួយចំនួននៅក្នុងគណបក្សប្រជាជននៅយល់នៅឡើយថា"ល្ងើយណាស់" ពីព្រោះនៅជិតអំណាចពេកទៅមិនបានធំក្លិនពិសពុលនៃគ្រាប់ពូជ "របបគ្រួសារ ហ៊ុន សែន និយម" ដែលកំពុងតែធ្វើដំណើរយ៉ាងលឿនទៅមុខនោះទេ។ របបនេះនឹងមិនបំរើឱ្យនរណាផ្សេងក្រៅពី"គ្រួសារ ហ៊ុន សែន " នឹងចរន្ត"ហ៊ុន សែន" តែប៉ុណ្ណោះទេ អ្នកឯទៀតងើបមុខរួចឡើយ។

ឆ្នាំ២០១៦នេះ គេកំពុងឃើញការផ្លាស់ប្តូរនយោបាយរបស់"របបគ្រួសារ ហ៊ុន សែន និយម" ទៅរកការបន្ថយពុករលួយបន្ថយការរឹបអូសយកដីប្រជាជនបន្ថយភាពក្រីក្ររបស់កម្មករនឹងរាជការបន្ថយការកាប់ព្រៃឈើបង្កើនការដាក់ទោសក្រុម"គ្នាគាត់"ខ្លះៗមានជម្រុញ "កូនក្មួយ"ឱ្យឡើងមកបន្តអំណាចខ្លះហើយ...។ល។ តែ "ខ្យល់"បានក្លាយជា"ព្យុះ"ទៅហើយលោកនាយករដ្ឋមន្ត្រីដ៏មហិមាមិនអាចប្តូរនយោបាយឱ្យគេជឿបានដោយមិនប្តូររចនាសម្ព័ន្ធជាតិនោះទេ -ដូច្នេះអ្វីដែលគេកំពុងឃើញថា មានការផ្លាស់ប្តូរនោះ គឺនៅក្នុង"គម្រោងរៀបចំបន្លំភ្នែក"របស់"របបគ្រួសារ ហ៊ុន សែន និយម" សម្រាប់ឱកាសបោះឆ្នោត នាឆ្នាំខាងមុខ។ ប្រទេសកម្ពុជាបានចុះហត្ថលេខាជាមួយអង្គការសហប្រជាជាតិថា នឹងធ្វើកម្ពុជាឱ្យទៅជា"ប្រទេសឯករាជ្យ-សេរី-ពហុបក្ស" ក៏កំពុងក្លាយជាចរន្តប្រឆាំងនឹង"របបគ្រួសារ ហ៊ុន សែន និយម" ជារឿងរហូតទៅហើយ! តើលោក ហ៊ុន សែន អាចហែលបញ្ច្រាសចរន្តនោះបានយូរប៉ុណ្ណា?

ចុងឆ្នាំ២០១៥ ហ៊ុន សែន បានប្រញាប់ឱ្យបញ្ហា"ធ្វើទុក្ខ"រាស្ត្រ-កម្មករនឹងគណបក្សប្រឆាំងរហូតដល់ប្រើហឹង្សាដែលជាសញ្ញាយកឈ្នះដោយ"កម្លាំងបាយ"...តែកម្លាំងតស៊ូប្រឆាំងនឹងរដ្ឋអំណាចរឹតតែរីកធំឡើងដែរ ហើយក្នុងរូបភាពផ្សេង ដែលហ៊ុន សែន ចាប់ផ្តាក់គណបក្សប្រឆាំងលែងបាន។ ឆ្នាំ២០១៦ យើងនឹងឃើញការប្រញាប់"ធ្វើទុក្ខ"រិតតែរន្ថើនឡើង ពីព្រោះនៅប្រកិតនឹងឆ្នាំបោះឆ្នោតខ្លាំងណាស់ទៅហើយ គាត់តម្រូវធ្វើឱ្យ"កម្លាំងបាយ"យកឈ្នះ"កម្លាំងឆ្នោត"ដែលចំនួនអាសនៈបក្សប្រឆាំងកើនឡើងមិនឈប់ឈរឱ្យបានមុនបោះឆ្នោតសាកល។ ក៏ប៉ុន្តែពេល "យកឈ្នះឆ្នោត"របស់លោក ហ៊ុន សែន អស់ទៅហើយ បង្ខំធ្វើបាបអ្នកដ៏ទៃរិតតែធ្វើឱ្យបាត់បង់សម្លេងឆ្នោតកាន់តែច្រើន។ នៅសល់គំនិតមួយទៀត ដែលគេសង្ស័យថានឹងមកដល់នៅពេលបោះឆ្នោតរួចភ្លាម គឺ "ក្រាញ ហើយមិនព្រមផ្ទេរអំណាច"...នេះជាខ្សែរឿងភាគថ្មីមួយទៀត ដែលបើគេលេងបៀរគេឱ្យឈ្មោះថា"ដាក់ផុក"ដែលយើងនឹងសូមជូនទស្សនៈក្នុងបទវិភាគពេលក្រោយទៀត។

ថ្វីត្បិតតែវិបត្តិសង្គមខ្មែរកើតមានរាល់ថ្ងៃមែន តែប្រជាពលរដ្ឋ កម្មករ ជាអ្នករងគ្រោះគ្រប់ទីកន្លែង ធ្វើបានល្អណាស់ដោយបង្ហាញឆន្ទៈតបតប្រកបដោយភាពក្លាហាននឹងដោយសន្តិភាព រីឯគណបក្សសង្គ្រោះជាតិជាគណបក្សប្រឆាំងដ៏ធំតែមួយរងគ្រោះដូចគ្នា តែតទល់រដ្ឋអំណាចយ៉ាងឆ្លាតវៃ រក្សាជំហ៊ររួបរួមគ្នាយ៉ាងរឹងប៉ឹងមិនទន់ជង្គង់នៅចំពោះទឹកលុយ ឬចំពោះការរំលោភដោយហឹង្សាទាំង២ក្រុមនេះ ជារងើកភ្លើងផ្តល់កំដៅដល់ប្រជាជាតិឱ្យនៅងំរង់ចាំតែឱកាស "បោះឆ្នោត"មកដល់តែប៉ុណ្ណោះ។ នៅសល់ក្រុមប្រជាជនដែល"មិនរងគ្រោះដោយចំពោះ"ដ៏ធំមួយទៀតដែលមិនអាចលេបថ្នលេបគ្រួសដោយគេមើលឃើញថា ហ៊ុន សែន កំពុងលក់ស្រុកខ្មែរឱ្យទៅវៀតណាមបំផ្លាញសម្បត្តិជាតិនិងប្រជាជនខ្មែរប្រាថ្នាយកប្រទេសខ្មែរជាសម្បត្តិផ្ទាល់ខ្លួនក្រុមនេះក៏ជាបាតដៃទី៣ នៃកម្លាំងប្រឆាំងដែរ នឹងមិនឱ្យ"ឆ្នោតខ្លួន"ទៅក្រុម ហ៊ុន សែន ទេ។

ឆ្នាំ២០១៦នេះ គេនឹងឃើញថា នយោបាយកាចសាហាវ គឺនៅតែជាការភ្លាត់ស្នៀតនឹងបានជា"ប្រយោជន៍ដល់ជនរងគ្រោះ" នៅក្នុងការបោះឆ្នោតឆ្នាំ២០១៧-១៨ជាមិនខាន។

**(បទវិភាគនេះ មិនមែនជាបទវិភាគកាន់ខាងបក្សប្រឆាំងទេ គឺជាវិភាគឯករាជ្យយោងតាមស្មារតីសេរីនឹងប្រជាធិបតេយ្យ)**




# ការផ្សាយបន្តផ្ទាល់ពី"ការបោះឆ្នោតបឋម" លើទូរទស្សន៍ឆានល់លេខ៨ ថ្ងៃទី១មិនា ពីម៉ោង ៧:៣០–៩:៣០ យប់

**ខែកុម្ភៈ ១២, ២០១៦**

លោកអ្នកអាចតាមដានការយកព័ត៌មានបន្តផ្ទាល់ពី"ការបោះឆ្នោតប្រធានាធិបតីបឋម" តាមទូរទស្សន៍"អិលធីស៊ី"ឆាណល់លេខ៨ ដែលជាការផលិតផ្ទាល់របស់ LTC អង្គការទូរគមនាគមន៍ក្រុងឡូវែលអំពី"សូពៃធូសដេយ ទី១មិនាឆ្នាំ ២០១៦" ដែលនឹងផ្តើមឡើងនៅម៉ោង៧កន្លះយប់។

"អិលធីស៊ី"នឹងសហការណ៏ផលិតព័ត៌មានជាមួយផលិតករសហគមន៏៣នាក់ដែលល្បីឈ្មោះមាន ជីម ភីទ័រ- ជន ម៉ាកដណាហ្វ នឹង ជច អេន។

វេនឌី ប្លូម ជានាយក"អិលធីស៊ី"ថ្មី និយាយថា "យើងរីករាយណាស់ដែលបានផ្តល់ព័ត៌មានពីលទ្ធផលនៃការបោះឆ្នោតដែលចេញភ្លាមៗ -យើងមុខតែនឹងសប្បាយនឹងមើលការបោះឆ្នោតក្នុងតំបន់ភ្ជាប់គ្នានឹងអត្ថាធិប្បាយរបស់ពិធីករដ៏ល្បីល្បាញរបស់យើង"។

បើតាម ភីទ័រ "អិលធីស៊ី"បានធ្វើព័ត៌មានភ្លាមៗកាលពីបោះឆ្នោតតំបន់ចុងក្រោយនេះមានអ្នកចេញទៅបោះឆ្នោត១៨,០៨% -លើកនេះគាត់មានសង្ឃឹមថា អ្នកបោះឆ្នោតនឹងមានច្រើនជាងមុន "គេត្រូវការចងចាំថា តើនឹងមានសារសំខាន់ប៉ុណ្ណា ដែលគេចេញទៅបោះឆ្នោតនោះ? ឡូវែលស្វាគមន៏ការចូលរួមកាន់តែច្រើនឡើងរបស់សហគមន៏អាស៊ីអាគ្នេយ៏នឹងគ្រប់សហគមន៏នៅក្នុងក្រុងទាំងអស់" ភីទ័រ គិតថាភាពងាយស្រួលនឹងមើលលទ្ធផលពីមណ្ឌលមួយទៅមណ្ឌលមួយទៀត ដូចដែលវាមកដល់សាលាក្រុងឡូវែលដែរ វានឹងប្រមូលអ្នកមើលកាន់តែច្រើន។

លោក ម៉ាក ដណាហ្វ នឹងបញ្ជូនព័ត៌មានដែលមកដល់ភ្លាមៗនោះ មកលោក អេន នឹង ភីទ័រ ដែលនៅប្រចាំការនឹងស្ទូឌីយោ"អិលធីស៊ី"។ មានអ្នកស្ម័គ្រចិត្តក្នុងសហគមន៏ជិតខាង ជាពិសេសក្រុម"ស៊ីធីឡាយ"ដែលនៅ"ឆែមហ្វើត"នឹងនៅ"ធិងបូរ៉ូ" ក៏នឹងបញ្ជូនលទ្ធផលបូកសរុបនៃតំបន់របស់គេមកដែរនោះ ធ្វើឱ្យកម្មវិធីទូទស្សន៍នេះក្លាយជា"ការផ្សាយរបស់ភូមិភាគ"តែម្តង។

សូមបើកមើលឆាណល់លេខ៨ ឬក៏ទៅមើល"ឡាយស្ត្រីម"ការផ្សាយកម្មវិធីនៅអស័យដ្ឋាន www.LTC.org/watch ដែលនឹងផ្តើមឡើងនៅម៉ោង៧កន្លះ ។ សូមអញ្ជើញមើលកម្មវិធីដោយរីករាយ!

# Live Lowell Primary Election Coverage, March 1, 2016, 7:30 – 9:30pm on LTC Channel 8

**February 12, 2016**

Watch live coverage of the US Presidential Primary Election on LTC Channel 8. Lowell Telecommunications Corporation (LTC) will cablecast its own coverage of Lowell Election Night on Super Tuesday, March 1, 2016 beginning at 7:30PM.

LTC will collaborate on the production with three well-known community producers, Jim Peters of "Peters' Principles," and "City Life" producers John McDonough and George Anthes.

Wendy Blom, the new Executive Director at LTC, stated, "We are so happy at LTC to provide real-time local election results. It will be fun to watch as the local votes are tallied, with commentary by three of LTC's popular show hosts."

According to Peters, LTC provided real-time election results for the last local election, which had a low turnout of 18.08%. He is expecting a much bigger turnout for this one. "People need to remember how important it is to come out and vote. Lowell welcomes heightened participation by the Southeast Asian communities, and in fact, all communities in the City." Peters thinks that the ease of watching Lowell's results, ward by ward as they come from Lowell City Hall, will garner a large audience.

Mr. McDonough will be forwarding the results as soon as they are posted to Mr. Anthes and Mr. Peters in the LTC studio. Volunteers from neighboring communities, especially "City Life" participants in Chelmsford and Tyngsborough, will also forward their tallies to give the show a regional reach.

Tune in to Channel 8 or watch the live stream of the show at www.LTC.org/watch beginning at 7:30pm. Enjoy the show!

Contact: Wendy Blom, Executive Director, wblom@ltc.org, 978-364-5141

246 Market Street, Lowell, MA 01852 978-458-5400 www.LTC.org

# អភិបាលក្រុង មាទីន ជេវាល់ MartinJ.Walshបង្ហាញនូវវិធីសុវត្ថិភាពដោះស្រាយនៅអាកាសធាតុត្រជាក់នាពេលខាងមុខ

**បកប្រែដោយៈ តារាយុទ្ធ ហង្ស**

បូស្តុន-ថ្ងៃព្រហស្បតិ៍ខែកុម្ភៈ ទី១១ឆ្នាំ ២០១៦ ជាមួយនឹងអាកាសធាតុត្រជាក់ និងត្រជាក់ញាក់ក្រោមអត្រាការព្យាករណ៏ កាលពីថ្ងៃចន្ទ អភិបាលក្រុងលោក ម៉ាទីន ជេ.វ៉ាល បានរំលឹកប្រជាជនក្នុងការទទួលយកការប្រុងប្រយ័ត្ននឹងស្វែងរកនៅកន្លែងដែលមានសុវត្ថិភាព។ អ្នកព្យាករណ៏បានទស្សទាយថា អាកាសធាតុនឹងធ្លាក់ចុះជាអតិបរមាអវិជ្ជមាន៤អង្សានៅថ្ងៃសៅរ៍ និងអវិជ្ជមាន២អង្សានៅថ្ងៃអាទិត្យនេះ។

អ្នកស្រុកត្រូវបានលើកទឹកចិត្តឱ្យត្រួតពិនិត្យមើលនៅលើសុខុមាលភាពមនុស្សចាស់ ឬជនពិការដែលនៅជិតខាង ឬក៏បុគ្គលដែលគ្មានផ្ទះសម្បែងដែលប្រហែលជាអាចត្រូវការជំនួយនិងជំរុញឱ្យមានការអនុវត្តការដ៏ប្រុងប្រយ័ត្នមួយ នៅពេលប្រើឧបករណ៏កំដៅចល័តដូចជាកម្តៅទឹកន្លែង។

អ្នកស្រុកត្រូវបានគេលើកទឹកចិត្តផងដែរក្នុង

**តទៅទំព័រទី ២០**



# MAYOR WALSH ISSUES SAFETY TIPS AHEAD OF BITTERLY COLD WEATHER

BOSTON - Thursday, February 11, 2016 - With cold weather and below-freezing wind chills forecast through Monday, Mayor Martin J. Walsh is reminding residents to take precautions to stay safe. Forecasters are predicting a low of negative 4 degrees on Saturday, and negative 2 degrees on Sunday.

Residents are encouraged to check on the well-being of elderly or disabled neighbors, be mindful of homeless individuals that may need assistance, and practice caution when using portable heating devices such as space heaters.

Residents are also encouraged to sign up for notifications from AlertBoston, the city's notification system, and to call 311, download the BOS:311 app, or tweet at @BOS311 with questions or concerns. For additional information on how to stay safe this winter,visit cityofboston.gov/cold and follow @CityOfBoston on Twitter.

**Contined to Page 27**

តមកពីទំព័រទី ១៩

## លោក ហ៊ុន សែន ច្រានចោលការរិះគន់...

មានការតវ៉ាណាមួយធ្វើឡើងប្រឆាំងរូបលោកនោះ វាអាចនឹងនាំឱ្យមានបាតុកម្មតបតវិញនៅកម្ពុជា ហើយអ្នកគាំទ្រគណបក្សកាន់អំណាចបាននិយាយថា អាចនឹងមានការឆ្លើយតបដោយហិង្សាប្រឆាំងមន្ត្រីគណបក្សសង្គ្រោះជាតិ។

គណបក្សប្រឆាំងបានលើកឡើងម្តងហើយម្តងទៀតថា ខ្លួនមិនពាក់ព័ន្ធជាមួយនឹងសកម្មជនសម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំងទេ។

នៅក្នុងសារបង្ហោះលើទំព័រហ្វេសប៊ុករបស់ខ្លួនកាលពីម្សិលមិញ ប៉ុន្មានម៉ោងមុនការតវ៉ារបស់សម្ព័ន្ធមិត្តខ្មែរ-អាមេរិកាំងចាប់ផ្តើមនោះ លោក ហ៊ុន សែន បានលើកឡើងថា ការធ្វើបាតុកម្មមានតែផ្តល់ផលប្រយោជន៍ទៅឱ្យអ្នករិះគន់ដែលជាបរទេសទៅវិញទេ។

លោកបានសរសេរថា "សូមមេត្តាកុំទាស់គ្នាក្នុងស្រុក ហើយមកទាស់គ្នានៅក្រៅស្រុក ហែកហួរបំផ្លាញសេចក្តីសុខរបស់ខ្មែរឱ្យបរទេសជាន់ឈ្លីមើលងាយជាតិសាសន៍យើង"។

ពីមុនលោក ហ៊ុន សែន ធ្លាប់បានបង្ហាញភាពរសើបរបស់លោកចំពោះការតវ៉ាធ្វើឡើងប្រឆាំងរូបលោកនៅក្រៅប្រទេស។ បន្ទាប់ពីលោកបានជួបនឹងការតវ៉ាអំឡុងដំណើរបំពេញទស្សនកិច្ចទៅកាន់ប្រទេសបារាំងកាលពីខែតុលា លោកបានព្រមានពីការតវ៉ាតបតវិញ។ នៅថ្ងៃ



Prime Minister Hun Sen claps during an event at a hotel in Southern California on Sunday evening. (AKP-TVK)

បន្ទាប់មកទៀតតំណាងរាស្ត្រគណបក្សប្រឆាំងចំនួនពីររូបត្រូវបានវាយដំឱ្យរបួសធ្ងន់អំឡុងការតវ៉ាប្រឆាំងគណបក្សសង្គ្រោះជាតិនៅខាងក្រៅរដ្ឋសភា។

កាលពីសប្តាហ៍មុនគណបក្សសង្គ្រោះជាតិ បានផ្ញើលិខិតទៅឱ្យក្រសួងមហាផ្ទៃ និងសាលារាជធានីភ្នំពេញដោយស្នើឱ្យមានការបង្កើនការការពារដើម្បីឆ្លើយតបទៅនឹងការគំរាមធ្វើបាតុកម្មតបតដ៏ហិង្សា។

នៅក្នុងលិខិតផ្ញើជូនលោក ប៉ា សុជាតិវង្ស អភិបាលរាជធានីភ្នំពេញកាលពីម្សិលមិញលោក ម៉ន ផល្លា ប្រធានគណៈកម្មាធិការប្រតិបត្តិរបស់គណបក្សសង្គ្រោះជាតិនៅក្នុងរាជធានីភ្នំពេញបានដកស្រង់ចេញពីវីដេអូមួយបង្ហោះតាមទំព័រហ្វេសប៊ុករបស់បុរសម្នាក់ឈ្មោះ សាំង សុង ដែលនិយាយថា ក្រុមរបស់ខ្លួន គឺក្រុមសម្ព័ន្ធយុវជននិងអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា (Youth Alliance and CPP Supporters) នឹងធ្វើការតវ៉ាតបតវិញ ប្រសិនបើបាតុកម្មនៅតែបន្តធ្វើនៅសហរដ្ឋអាមេរិក។

លោក សាំង សុង បាននិយាយក្នុងវីដេអូនេះថា "ប្រសិនបើការបំពេញទស្សនកិច្ចផ្លូវរដ្ឋរបស់សម្តេចឱ្យ ហ៊ុន សែន" ដើម្បីចូលរួមកិច្ចប្រជុំកំពូលអាស៊ាន...ត្រូវបានទទួលស្វាគមន៍ដោយបាតុកម្មប្រឆាំងរូបលោកនោះ យើងនឹងធ្វើបាតុកម្មនៅខាងមុខទីស្នាក់ការកណ្តាលរបស់គណបក្សសង្គ្រោះជាតិ ហើយស្នើឱ្យរដ្ឋសភាទម្លាយគណបក្សនេះចោល"។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានលើកឡើងកាលពីម្សិលមិញថា លោកមិនស្គាល់ថា លោក សាំង សុង ជានរណាឡើយ ប៉ុន្តែលោកគាំទ្រសិទ្ធិរបស់គាត់នៅក្នុងការធ្វើការតវ៉ាបែបនេះ។

លោកបានមានប្រសាសន៍ថា "គណបក្សប្រជាជនកម្ពុជាមិនបានរៀបចំបាតុកម្មដើម្បីប្រឆាំងអ្នកនេះ ឬអ្នកនោះឡើយ"៕

តមកពីទំព័រទី ១៩

## អភិបាលក្រុង ម៉ាទីន ជេវ៉ាល់...

ការចុះឈ្មោះសម្រាប់ការជូនដំណឹងពីភាពអាសន្នAlertBoston, ប្រព័ន្ធការជូនដំណឹងរបស់ទីក្រុងនេះ និងដើម្បីហៅ ៣១១,ដោនឡោដ (download) កម្មវិធី BOS:311 ឬក៏ Tweet តាមអាស័យដ្ឋាន @ BOS311 បើសិនជាមានសំណួរ ឬការព្រួយបារម្ភណាមួយ។ ចំពោះព័ត៌មានបន្ថែមអំពីរបៀបដើម្បីរក្សាសុវត្ថិភាពនៅរដូវរងារនេះ,សូមទៅកាន់គេហទំព័រ cityofboston.gov/cold និងរ៉ោល្វ (follow)@CityOfBoston នៅលើ Twitter ។

អភិបាលក្រុង Walsh បានថ្លែងថា "បញ្ហានៃសីតុណ្ហភាពទាបបានផ្តល់នៅផលវិបាកចំពោះទីក្រុង និងប្រជាពលរដ្ឋរបស់យើងហើយពួកយើងកំពុងធ្វើការដើម្បីតាមដានស្ថានការណ៍ និងរក្សាអ្នកស្រុកទាំងអស់របស់យើងឱ្យមានសុវត្ថិភាព"។ "ខ្ញុំបានសង្ឃឹមថា ពលរដ្ឋនៅក្នុងទីក្រុងបូស្តុនទីមួយៗនឹងមានសុវត្ថិភាពនឹងចេះមើលថែអ្នកជិតខាងរបស់ខ្លួន"។

**បង្ការថយចុះកម្តៅ និងរលាកកិត**

ស្លៀកពាក់សម្រាប់អាកាសធាតុនេះពាក់ស្រទាប់ជាច្រើនដែលទំងន់ស្រាល,សម្លៀកបំពាក់ក្តៅរលុងជាជាងសម្លៀកបំពាក់មួយដែលមានស្រទាប់ធ្ងន់។

សម្លៀកបំពាក់ក្រៅគួរតែត្រូវបានត្បាញយ៉ាងតឹងរឹងនិងមិនជ្រាបទឹក។

